# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ប៉ូច សំណាង

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ប៉ូច សំណាង

## ការសង្ខេបរបស់អ្នកមីង ប៉ូច សំណាង

នៅក្នុងការសំភាសន៍លើកនេះគឺអ្នកមីងបានប្រាប់ពីជីវិតដែលជាស្រ្តីម្នាក់ត្រូវប្តីធ្វើបាបវាយតប់ហើយទៅមានស្រីហើយបានធ្វើអោយមានរឿងកើតឡើងរហូតដល់ថ្នាក់លេងលះគ្នាហើយកូនត្រូវពិបាក ។
បន្ទាប់ពីលេងលះគ្នាអ្នកមីងបានខូចចិត្តជាខ្លាំងហើយដើរផឹកស្រាស្ទើរតែរាល់ថ្ងៃហើយបានធ្វើអោយកូនគាត់ពិបាកព្រោះតែម្តាយ
តែដោយសារកូនរបស់គាត់ធំឡើងបានចូលព្រះវិហារសាសនាគ្រីស្ទ
ហើយបានណែនាំគាត់អោយចូលដែលហើយក៏គាត់ចាប់ផ្តើមមានជីវិតជាថ្មី
ហើយឈប់ទទួលស្រាទៀត
នេះដោយសារជាបញ្ញត្តិរបស់ព្រះគឺគាត់អាចគោរពហើយចាប់ផ្តើមមានជីវិតដ៏ស្រស់បំព្រងឡើងវិញម្តងទៀត។
ហើយគាត់ផ្តាំអោយកូនចៅគាត់ជំនាន់ក្រោយដើរលើផ្លូវនេះដែរដើម្បីក្លាយខ្លួនទៅជាមនុស្សដ៏ល្អ។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិអ្នកមីងម្តងទៀតជាលើកទី២ ។នាងខ្ញុំឈ្មោះញ៉ែម
សុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកថី ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។
អ៊ីចឹងដោយសារពេលមុនពួកយើងបានសំភាសន៍អំពីជីវិតខ្លះៗរបស់អ្នកមីង
ប៉ុន្តែអត់បានក្បោះក្បាយទាំងអស់ទេអ៊ីចឹងចង់អោយអ្នកមីងប្រាប់ពីជីវិតរបស់អ្នកមីងអើរពីមុន

ពីមុនមកថែមទៀតក៏ដូចជាសេចក្ដីសង្ឃឹមសំរាប់ទៅអនាគតអ៊ីចឹងហាំអ្នកមីង!!អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះម្ដងទៀតមើល!!

ខ៖ ឈ្មោះប៉ូច សំណាង!!

ក៖ អ្នកមីងសំរាប់អ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់វិញ?

ខ៖ អើរមើលកាលពីមុនមានប្រុសពីរ តែស្លាប់មួយនៅសល់មួយទេ!!

ក៖ ចាំទាំងស្លាប់ទាំងរស់មានប៉ុន្មាននាក់ទាំងអស់?

ខ៖ ប្រុសពីរស្រីបី។

ក៖ ចាំគាត់ឈ្មោះអីគេខ្លះអ្នកមីងអាចប្រាប់?

ខ៖ ឈ្មោះអើយដំបូងញុំមឈ្មោះប៉ូច សំណាង បន្ទាប់មកប៉ូច ចាន់និត !!ប៉ូច ចាន់និតហើយប៉ូច ចំណាប់ ប៉ូច ចំណាប់ហើយប៉ូច ចំណាន !ប៉ូច ចំណានហើយប៉ូច ភារ៉ូត។

ក៖អ៊ីចឹងអ្នកមីងបានប្រាប់ដូចកាលពីមុនគឺប្អូនប្រុសមួយពិបាកម៉ងហោ?

ខ៖ ហ្នឹងហើយ ហ្នឹងអាពៅគេហ្នឹងក្រោយគេប៉ូច ភារ៉ូតហ្នឹងហើយ។

ក៖ ចាំ!!អាយុប៉ុន្មានបានជាខូចអីក៏ខូចម្លេះ?

ខ៖ ២០ជាងហើយវា!!

ក៖ តែមានប្រពន្ធមានកូនមួយ!!!
តែបើប្អូនមួយដែលស្លាប់ទៅនោះដោយសារគ្រោះថ្នាក់ចរាចរណ៍?

ខ៖ ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍។

ក៖ហ្នឹងហើយលឺអ៊ំនិយាយប្រាប់។ខ៖ចាំ!!ក៖ហ្នឹងហើយគាត់
ហ្នឹងហើយអ្នកគេចង់ដឹងពីប្រវត្តិអាស្ដាប់របស់អ៊ំបាន!!អូខេអ៊ីចឹងសំរាប់បងប្អូនអ្នកមីងតាំងពីក្មេងៗមកចូលចិត្តលេងអីគេខ្លះជាមួយគ្នាវិញ?

ខ៖ ញុំមហោញុំមអត់ចាំកាលពីនៅពីក្មេងៗម៉េចទេញុំម!!

កៈ ម៉េចអញ្ចឹងវិញ?

ខៈ
ស៊ីស្ទើរញ៉ុមបានឥឡូវញ៉ុមទៅវិហារញ៉ុមរាងទៅភ្លេចទេ!!កៈចាំ!!ញ៉ុមគ្រាន់តែគ្រោះថ្នាក់៣ដង
ក្បាលហាំ!!

កៈម៉េចវិញ?

ខៈ ដួលម៉ូតូបែកក្បាលពេលជិះមកពីធ្វើការនោះមួយសារ
មួយសារអញ្ចឹងគេដេរទៅមួយសារបែកក្បាលមួយសារ
ដេរបានមួយសារហើយរំលងបានប៉ុន្មាននេះដួលមួយសារទៀត ដួលនឹងផ្ទះគេ
ដួលនឹងផ្ទះគេផ្ទះខ្ពស់អ៊ិចឹងគេមិនមានជើងតាងក្រោម!!

កៈចាំ!!

ខៈហើយញ៉ុមអង្គុយៗជជែកជាមួយគេអ៊ីចឹងហិ អង្គុយៗងងឹតមុខអញ្ចឹងហាំ ដួលមកចំ
ចំហ្នឹងរយ៉ាស់!!

កៈកន្លែងដដែល?

ខៈ កន្លែងផ្សេងតែក្បាលដដែល។

កៈចាំ!!

ខៈ ៣សារ ដល់ពេលមកសារក្រោយនេះផ្ងាក្រោយ
ដល់ពេលមកដេរសារក្រោយនេះញ៉ុមបាត់ការចងចាំច្រើនម៉ង!!
ឃើញញ៉ុមទៅឃើញស៊ីស្ទើរពន្យល់មែនតែដល់ពេលហ្នឹង ភ្លេចអស់ហើយ!!

កៈ យល់តែពេលហ្នឹងហោ?

ខៈ ញ៉ុមយល់តែពេលហ្នឹងទេ ហើយកុំសួរញ៉ុម ញ៉ុមអត់ដឹងទេ!!

កៈចាំ!!

ខះហ្នឹងហើយសូម្បីអាអូនក៏ដោយពេលមកពេលប្រាប់ញ៉ុមអញ្ចេះអញ្ចេះញ៉ុមក៏ភ្លេចលឿន
វាថាហុីញ៉ុមធុញនឹងប្រាប់ម៉ែឯងណាស់មែនតើ!!ហើយឆាប់ភ្លេច!!

កះ អ្នកណាគេចង់អីចឹងបើជួបគ្រោះថ្នាក់អញ្ចឹងហើយ!!

ខះ ចាំអញ្ចឹងបានញ៉ុមឥឡូវញ៉ុមអត់សូវចេងចាំទេ!!កះចាំ!!ខះ
អញ្ចឹងបានញ៉ុមទៅហ្នឹងហ្ន៎!!បានស្តាប់ ពេលស្តាប់អញ្ចឹងអាកន្លែងចំនុចណាត្រូវញ៉ុមចាំចាំទៅ
កន្លែងណាអត់អត់ទៅ!!

កះ ហុីសូម្បីតែញ៉ុមអត់ធ្លាប់មានគ្រោះថ្នាក់អីពេលខ្លះក៏ភ្លេចដែរមីងអើយ!!

ខះហ្នឹង!!

កះវាមិនមែនអង្គុយតែចាំទាំងអស់ណា!!

ខះ អត់ទេតែគ្រាន់តែការចេងចាំរបស់ញ៉ុមបាត់ច្រើន!!

កះចាំ!!

ខះតាំងពីមានបញ្ហាខួរក្បាលមកញ៉ុមអត់ដែលថាអូទៅស្កែនមើលក្បាលម៉េចអត់ទេ៕

កះ អត់ដែលទេអញ្ចឹងហេ?

ខះ អត់ដែលទេ!! គ្រាន់តែដេរពាសារ អាក្រោយនេះប៉ុន្មានថ្ងៃ ៣ ៤ ៥ថ្ងៃរចំហៀងនេះ
និយាយទៅកាលញ៉ុមដេរដំបូងហាំពេទ្យថារកកោរសក់ញ៉ុមផង
ដល់ហើយញ៉ុមអោយគេកោរទេអោយគេកាត់ហាំ!!
កាត់ហើយដូចថាស្កេលតែកន្លែងអារង្វង់ហ្នឹងទៅណាស់!!ហើយអោយគេដេរទៅណាស់!!

កះហុីៗ!

ខះហើយឈាមហូរជោគសក់ជោរអី។

កះ ហុីញ៉ុមធ្លាប់គេកប់ក្បាលដែរមួយដំថ្ម មិនដឹងដុំដីឬក៏ដុំថ្មទេ
ដាក់ពាំង!!មុជទឹកស្រះហ្ន៎មីង!!គប់លេងឈ្លោះគ្នាម៉េចទេ
នៅក្មេងៗលេងម៉េចទេញ៉ុមមិនដឹងទេផ្លោងមកចំក្បាលហ្នឹងឡើងរយ៉ាស់!!ដេរប៉ុន្មានថេរដែរតើ

!!៥ថ្មេរ
ពេលនៅក្មេងៗអញ្ចឹងនៅក្មេងៗអញ្ចឹងហើយ!!តែអ្នកមីងដោយសារងងឹតមុខងងឹតអីអញ្ចឹងទៅ
!!ចេះតែអញ្ចឹងទៅ!!

ខ៖ចាំ!!

ក៖អញ្ចឹងអ្នកមីងសំរាប់បងប្អូនទាំងអស់ហ្នឹងហាំ!!អត់សូវចាំថាលេងអីគេជាមួយគាត់ទេហោ?

ខ៖ អត់ដឹងថាមានលេងអីជាមួយទេ!!

ក៖ តែទាំងអស់គ្នាសុទ្ធតែបានទៅរៀនទាំងអស់គ្នាតើហី?

ខ៖ ទៅរៀនទាំងអស់គ្នា។

ក៖ចាំ!!ទៅរៀនមានដែលឌុបប្អូនទៅរៀនឌុបទៅរៀនទេ?

ខ៖អត់ទេ!!

ក៖ ទៅរៀនរៀងៗខ្លួនហោ?

ខ៖ទៅរៀងៗខ្លួន។

ក៖ កាលហ្នឹងម៉េចដែរអ្នកមីង?

ខ៖ កាលហ្នឹង កាលញ៉ុមរៀនថ្នាក់ទី៦ ទី៧
ណោះរៀននៅព្រែកតូចហ្នំ!!រៀននៅសាលាស្ពានព្រែកតូចហាំ!!ហើយដល់ពេលប្អូនញ៉ុម
ដល់ពេលប្អូនញ៉ុមទៅរៀនណោះបាត់ទៅ
គេចាប់ផ្តើមសាងសង់នូវសាលាឈូងលៀបយើងនេះហើយ!!

ក៖ហ៊ីៗ!!

ខ៖ ដល់ពេល ដល់ពេលសម័យប្អូនញ៉ុមដល់ពេលដល់ថ្នាក់ទី៦ទី៧គេរៀននៅនេះម៉ង!!

ក៖ចាំ!!

ខ៖រៀននៅហ្នឹងរហូតម៉ងអត់មានទៅណាណោះទៀតទេណាស់
គេបង្កើតសាលានៅនេះហើយ!!

ក៖ ចាំអញ្ចឹងស្រួលនៅណោះវិញទៅឆ្ងាយដែរហ្នឹង!!

ខ៖ ទៅឆ្ងាយដែរហ្នឹងធាក់កង់ទៅឆ្ងាយដែរហ្នឹងហាំ!!

ក៖ ព្រែកតូចឆ្ងាយ!!

ខ៖ ឆ្ងាយ!!ហ្នឹងធាក់កង់ទៅមួយហាត់ៗដែរ។

ក៖ មីងឥឡូវផ្លូវទៅណោះ ហួសទៅណោះទៅធំខ្លាំងទេ?

ខ៖ ធំនិយាយទៅផ្លូវប៉ុនគ្នារហូតទៅដល់ស្ពានព្រែកតូចហ្នុំ!!

ក៖ហ្នុំអីចឹងទៅដល់យួនទេ?

ខ៖ ទៅដល់។

ក៖ ផ្លូវធំៗអញ្ចឹងហាំ?

ខ៖ ទៅដល់ជ្រៃធំទៅដល់អីរហូតហ្នឹង ផ្លូវប៉ុណ្ណឹងរហូត!!

ក៖ហ្នុំ!!

ខ៖ប៉ុណ្ណឹងទៅតែរហូតហ្នឹង។

ក៖ គេពង្រីកហើយអស់ហើយហោ?

ខ៖ ពង្រីកហើយហើយ!!

ក៖ ដោយសារពេលមុនផ្លូវហ្នឹងតូចណាស់មីងណាស់!!

ខ៖ហ្នឹង!!

ក៖ពិបាកជិះណាស់!!ហើយអត់ស្អាតអីចឹងទេ
តែដល់ពេលឥឡូវគេដូចអភិវឌ្ឍន៍ទៅដូចឃើញគ្រាន់បើ។

ខ៖ចាំ!!

ក៖ល្មមអភីវឌ្ឍន៍យូរណាស់ហើយ!និយាយទៅធ្វើអញ្ចឹងគួរតាំងពីយូរណាស់ហើយដោយសារផុតពីសង្គ្រាមយូរណាស់មកហើយ!!ទឹមតែឥឡូវទឹមតែធ្វើ
ចាំអញ្ចឹងអ្នកមីងសំរាប់ការសិក្សាអ្នកមីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ថ្នាក់ទី៨។

ក៖អើររៀននៅសាលាបឋមសិក្សាណាវិញ?

ខ៖
កាលញ៉ុមរៀននៅសាលាបឋមសិក្សានៅព្រៃកថីយើងនេះឯងនេះនៅឈូងលៀបហាំនៅសាលាបឋមសិក្សាឈូងលៀបដល់ពេលបានអនុវិទ្យាល័យរៀននៅស្អាងព្រៃកតូច!!

ក៖ អនុវិទ្យាល័យស្អាងហ្នឹងហី?

ខ៖ ចាំ!!

ក៖ឆ្ងាយមីង!!

ខ៖
ឆ្ងាយហើយបានតែអនុវិទ្យាល័យហើយអាហ្នឹងញ៉ុមរៀនត្រឹមតែអនុទេញ៉ុមឈប់ហាំ!!ក៖ចាំ!!ខ៖វិទ្យាល័យហួសហ្នឹងទៀត!!

ក៖ចំ!!ញ៉ុមពេលប្រលងបាក់ឌុបញ៉ុមប្រលងនៅវិទ្យាល័យស្អាងហ្នឹង!!

ខ៖ហ្នឹង!!

ក៖ឆ្ងាយជិះពីតាខ្មៅមក តែគ្រាន់តែថាមកប្រលងហ្នឹងមានអី បាននិទ្ទេសគ្រាន់បើដែរ!!

ខ៖ចាំ!!

ក៖ល្អណាស់ចាំ!!

ខ៖ញ៉ុមចាំមើលញ៉ុមឈប់ត្រឹមឆ្នាំប្រលងដែរតើហើយគ្រូមកសួរថាម៉េចបានអត់បានទៅប្រលងកាលហ្នឹងប៉ាញ៉ុមឈឺហាំ!!ប៉ាញ៉ុមឈឺហើយបងប្អូនចេះតែថាហ្អែងឈប់ទៅ ឈប់អញ្ចឹងទៅញ៉ុមក៏ឈប់ទៅ អត់មានបានប្រលងឆ្នាំប្រលងតើ!!ហើយប្រលង ពេលប្រលងហើយគ្រូមកសួរតើរៀនជាមួយគាត់អ៊ីចឹងហាំគាត់មកហួបកាហ្វេហាំ!!

ក៖ចាំ!!

ខ៖ គាត់ទៅតាខ្មៅគាត់ចូលហួបកាហ្វេគាត់ចូលសួរញ៉ុមញ៉ុមថា គាត់សួរញ៉ុមជាប់ហើធ្លាក់អញ្ចឹងហាំ!!

ក៖ចាំ!!

ខ៖ ញ៉ុមថាលោកគ្រូញ៉ុមអត់បានទៅប្រលងផង អញ្ចឹងហាំ!!

ក៖ ស្តាយណាស់!!

ខ៖ ពេលហ្នឹងគាត់ថាអោយញ៉ុមដែរហ្នឹងថាអើយស្តាយណាស់!!

ក៖ ភាគច្រើនញ៉ុមអោយតែលឺថាអ្នកណាគេដល់ពេលប្រលងហើយអត់ទៅប្រលងហ្នឹងញ៉ុមស្តាយជំនួសគេម៉ង!!

ខ៖ មើលឈ្មោះមើលអីហើយហ្នឹង ហើយអស់ហើយដល់ពេលថ្ងៃប្រលងអត់បានទៅប៉ាញ៉ុមឈឺធ្ងន់ក្អកធ្លាក់ឈាមហ្នំ!!

ក៖ហូ!!

ខ៖ ក្អកធ្លាក់ឈាមទាំងកន្ថោរទាំងកន្ថោរហ្នំ!!អាម៉េចហ៊ានដើរចោលអីត្រូវការបូមទឹកទៀត បូមទឹកដាក់អោយគេដាក់អោយអី ហើយមានអ្នកណាគេបូម ញ៉ុមបងគេហើយនឹងប្អូនញ៉ុមអាប្រុសមួយទៀតហ្នំ!!តាថេតាថាសហើយនៅទូចដែរហ្នឹង!!

ក៖ ហើយប្រលងតែមួយថ្ងៃពីរតើហី?

ខ៖
ហ្នឹងប្រលងតែមួយថ្ងៃពីរហ្នឹងតែដូចឆ្លៀតអត់បានម៉ងដូចថាកាលហ្នឹងអត់មានអ្នកណាជួយម៉ែហ្ន៎កាលហ្នឹងម៉ែមានកូនទូចទៀត កូនទូចអាមួយប្រុសក្រោយហ្នឹង។

ក៖ ហ៊ឹៗ!!អូយពិបាកណាស់អីចឹងហ្ន៎!!

ខ៖ កូនប្រុសមួយអាទូចហ្នឹង!!ដល់ហើយវាពិបាកពេកអំរែកច្រើនពេក តាយាយញ៉ុមអីវ៉ាន់ហ្នឹងចេះតែនិយាយថាឈប់ទៅហ្នឹងហា៎!!ឈប់រៀនឈប់អីអឹចឹងទៅណាស់ ហើយមើលទៅញ៉ុមឃើញពិបាកដែរ!!

ក៖ ក៏ឈប់ម៉ងទៅ!!

ខ៖ ហ្នឹង!!

ក៖ចា៎!!

ខ៖ ហើយបូមទឹកបូមអីហើយរវៃម៉ាស៊ីនអញ្ចឹងគ្រាន់តែនេះទៅណាស់ អូយម៉ាស៊ីនចូលទន្លេត្រណាត់ត្រណៃងពីរនាក់បងប្អូនហា៎!!អាមួយប្រុសងាប់ទៅហ្នឹង។

ក៖
ចា៎ដូចជាអ្នកមីងសំរាប់ការសិក្សាអ្នកមីងនៅពីក្មេងអ្នកមីងមានក្តីស្រម៉ៃប្រាថ្នាអីថាធំឡើងចង់ធ្វើអីមួយអត់?

ខ៖
កាលហ្នឹងថាអត់មានប្រាថ្នាចង់អីទេចង់ចង់កាលហ្នឹងថាចង់រៀនភាសារៀនអីអោយចេះនឹងគេទៅណាស់!!!តែរៀនអីត្រឹមហ្នឹង
តែដូចថាយើងរៀនបានខ្លះដែរណាស់វាមិនបានច្រើនគេអឹចឹងតែចង់ដូចឃើញគេរៀនអញ្ចឹងគេធ្វើការគេចេះភាសាអីអញ្ចឹងគេស្រួលហា៎!!ចង់រៀនដែរដល់ពេលទៅពេលប៉ាឈឺប៉ាអីទៅឈប់ទៅ ឈប់រៀនឈប់ទាំងអស់ម៉ងហា៎!!

ក៖ ចា៎បំភ្លេចអីចោលទាំងអស់ម៉ង!!

ខ៖ បំភ្លេចអីចោលទាំងអស់!!

កៈ អត់បានបំពេញក្តីស្រម៉ៃធ្វើអីធ្វើអី!!

ខៈ អត់!!

កៈ អ្នកមីងពេលនៅសិក្សាហ្នឹងមានមានមិត្តភក្តិអីជិតស្និតអីអត់?

ខៈ មានតើកាលពេលនៅរៀន តែគេសុទ្ធតែនៅឆ្ងាយៗ!!

កៈចាំ!!

ខៈ ហើយឥឡូវគេមានប្តីគេមានប្រពន្ធគេអស់មានកូន!!

កៈ មិត្តភក្តិជិតស្និតជាងគេឈ្មោះអីគេវិញ?

ខៈ
ញ៉ុមថាជិតស្និតតែដល់ពេលគេការហើយដូចថាជិតស្និតតែពេលនៅរៀនហាំ!!ដល់ពេលការហើយលែងជិតស្និតជាមួយគ្នាដូចញ៉ុមដូចញ៉ុមការហើយញ៉ុមទៅនៅតាខ្មៅទៅគេនៅណោះទៅណាស់!!

កៈចាំ!!

ខៈហើយដូចថាយូរៗណាយពីគ្នាអស់ឃើញមុខហៅគ្នានិយាយអីចឹងទៅណាស់!!!បើថាឃើញអញ្ចឹងហ្អែងទៅណាស់ទៅណាអីចឹងទៅ!!តែដល់ពេលអត់ទៅទៅនៅផ្ទះរៀងខ្លួនសូម្បីតែញ៉ុមឥឡូវនៅតែផ្ទះដែរហ្នឹង អត់ធ្វើការអត់ទៅណា!!

កៈ អត់ធ្វើការអត់ដើរទៅណា?

ខៈ
ចាំ!!អត់ធ្វើការអញ្ចឹងទៅទៅព្រះវិហារទៅមកផ្ទះវិញនៅអង្គុយនៅផ្ទះហ្នឹង!!កៈចាំ!!ខៈជាមួយបងប្អូនញ៉ុមអញ្ចឹងទៅ!!

កៈហ្នឹងហើយ។

ខៈ ជាមួយក្មួយអីចឹងទៅ!!

កៈ
ព្យាយាមដើម្បីមានមិត្តភក្តិអោយច្រើនមីងនៅណោះដើម្បីដូចថាពួកគាត់សុទ្ធតែស្រួលៗអញ្ចឹងហាំ!!លោរពេលត្រូវការថ្ងៃអាទិត្យអឺចឹងទៅចង់ទៅណាទៅណីទៅសួរសុខទុកសមាជិកអីវ៉ាន់អញ្ចឹងទៅបានទៅសប្បាយជាមួយគ្នាអញ្ចឹង។

ខៈចាំ!!

កៈ
ហើយគេតែនេះគេមានសកម្មភាពរហូតហ្នឹង!!ដោយសារគេចង់អោយពួកយើងទាំងអស់គ្នាមានសាមគ្គីភាពគ្នាអញ្ចឹងទៅមីងណាស់!!ចាំ!!

ខៈ
ហើយស៊ីស្ទើរញ៉ុមចង់ដើរអញ្ចេកញ៉ុមចង់ទៅដោយសារអីគេនៅនេះសុទ្ធតែអ្នកគេមិនសូវល្អហាំ!!
មិនសូវល្អម៉េចភាគច្រើនញ៉ុមឃើញដូចថាឃើញគំរូរម៉ងហាំ!!អ្នកទៅអង្គុយផ្ទះគេភាគច្រើនមុនដំបូងនិយាយពីខ្លួនឯងដល់ពេលហើយចូលដល់និយាយរឿងពីអ្នកដទៃ!!កៈចាំ!!ខៈរឿងអ្នកដទៃមានបញ្ហា និយាយដើមគ្នាទៅវិញទៅមក
ហើយញ៉ុមមានអីមានតែទៅព្រះវិហារមកវិញមកផ្ទះបងប្អូនឯងលេង
បើបងញ៉ុមបើថាកូនម៉ែញ៉ុមគាត់យកមកចិញ្ចឹមហ្នឹងផ្ទះនៅខាងក្រោយហ្នឹងហាំ!!ពេលទៅពេលណាថ្ងៃអាទិត្យបើថាញ៉ុមអត់នៅនេះអញ្ចឹង ញ៉ុមទៅអង្គុយផ្ទះគាត់នៅណោះ !!

កៈចាំ!!

ខៈ មកពីហ្នឹងញ៉ុមទៅអង្គុយផ្ទះគាត់អញ្ចឹងទៅ
ហើយឥឡូវគាត់ទៅនៅព្រះវិហារបាត់បានញ៉ុមនៅអង្គុយនៅនេះហ្នឹងហិ!!មកពីគាត់ទៅនៅព្រះវិហារ!!

កៈ ខេត្តព្រះវិហារ?

ខៈចាំទៅនៅហ្នឹង!!

កៈ ចឹបានទៅនៅហ្នឹងវិញ?

ខ៖ គាត់មានកូននៅណោះ !!

ក៖ចាំ!!

ខ៖ កូនគាត់ទៅព្រះវិហារណោះហាំ!!ហើយគាត់ទៅលេងកូនគាត់ ហើយប្រហែលជាគាត់ចង់ទៅនៅណោះផងហាំ!!ព្រោះគេចែកដីអោយយើងនៅ ហើយដីហ្នឹងគេចែកអោយយើងលុះត្រាតែយើងទៅនៅដែរបានគេអោយបើយើងអត់នៅគេអត់អោយយើងទេ!!

ក៖ តែនៅព្រះវិហារនៅហ្នឹងឆ្ងាយណាស់មីងអើយ!!

ខ៖ឆ្ងាយ!!

ក៖ វាអត់មានដូចថាពិបាករកអីម៉ងហាំ!!

ខ៖ហ្នឹង!!

ក៖ទោះថាការចង់ទៅដើរលេងអីទៅណាក៏ឆ្ងាយពីគេដែរ!!

ខ៖ចាំ!!

ក៖
យើងនៅនេះអញ្ចឹងទៅចង់ទៅលេងសមុទ្រចង់ទៅលេងក្រុងទៅលេងអីចង់ទៅលេងបានទាំងអស់ ទៅសមុទ្រជិះ៤ ៥ម៉ោង ៣ម៉ោងអីវ៉ាន់អញ្ចឹងទៅទៅដល់ ទៅលេងវៀតណាមទៅបាន ទៅភ្នំពេញទៅបាន!!

ខ៖ បងញ៉ុមនឹកឃើញថាអញ្ចេកកូនគាត់មានប្តីចង់អស់ដែរហើយណាស់!!

ក៖ចាំ!!

ខ៖ហើយគាត់ចេះតែទៅណោះទៅលេងកូននៅណោះអញ្ចឹងទៅណាស់!!ទៅគេចែកដីចែកអី!!

ក៖បងកូនចិញ្ចឹមរបស់ម៉ែហ្នឹងហី?

ខ៖ ចាំ!!

កះចាំ!!អោយគាត់ទៅនៅណោះទៅហើយគាត់មើលថៅមើលអីផងហើយកូនគាត់ កូនប្រុសារគាត់មួយស្រីហ្នឹងគេអោយធ្វើគ្រូបង្រៀន គ្រូបង្រៀននៅព្រះវិហារណាស់!!

កះចាំ!!

ខះ ហើយកូនប្រុសហ្នឹងគេអោយដូចថាឥឡូវហ្នឹងធ្វើការដូចថាធ្វើពុម្ភអីអញ្ចឹងទៅណាស់!! គេអោយត្រូវប្រជុំណាអញ្ចឹងគេអោយហៅតាមភូមិដូចថាវារៀនបានខ្ពស់ហាំដូចថាវារៀនឡើង ចប់សកលវិទ្យាល័យហើយហ្នឹង!!

កះចាំ!!!

ខះ តែគ្រាន់តែវារៀនផ្នែកអត់ត្រូវប៉ាន់ ធ្វើការ ។

កះ អត់ចំជំនាញ!!

ខះ អត់ចំជំនាញណាស់!!

កះ ពិបាកដែរ!!

ខះ អញ្ចឹងបានម្នាក់ៗយ៉ាប់ណាស់ ស្អីសុទ្ធតែ អីគេគេរៀនសុទ្ធតែដល់មហាវិទ្យាល័យតែទៅកាប់ព្រៃនៅព្រះវិហារ បង្អាប់រហូតហ្នឹងហាំ!!

កះ ចេះតែឌីដងគ្នាហោ?

ខះ ហ្នឹងហ្នឹង!!!

កះ ហ្នឹងហើយពេលខ្លះ ពេលខ្លះឆ្លាតឆ្លាតមែនតែបើសិនជាអត់ឪកាសមកផ្តល់អោយមកអោយអញ្ចេះក៏ពិបាករកការ ងារដើម្បីធ្វើដែរ!!

ខះ ហ្នឹង!!

កះ អញ្ចឹងវាសំខាន់ ដើម្បីអោយមានឪកាសច្រើនអីចឹងណាស់!!

ខះហ្នឹង!!

កៈ
ពេលខ្លះអ្នកខ្លះរៀនអត់សូវពូកែទេប៉ុន្តែពួកគេមានឱកាសដោយសារទំនាក់ទំនងគ្នាអីវ៉ាន់អញ្ចឹងហ្នំ!!

ខៈចាំ!!

កៈអញ្ចឹងមានការងារមួយដែលល្អមកហើយ
អោយតែមានពួកម៉ាក់!!អីចឹងដូចសៀវព្រឹងអីចឹងគេរាប់អានពួកម៉ាក់គេច្រើនអញ្ចឹងណាស់
អញ្ចឹងអ្នកណាមានការងារមានអីអញ្ចឹងទៅតែគាត់ប្រាប់តគ្នា
អញ្ចឹងគាត់មានឱកាសដើម្បីធ្វើការទាំងអស់ហ្នឹងហើយ!!

ខៈចាំ!!

កៈអញ្ចឹងសំខាន់ណាស់អ្នកមីងការរាប់អានគ្នាជាមិត្តភក្តិហាំ!!

ខៈ តែស៊ីស្មើរកាលហ្នឹងញ៉ុមនៅធ្វើការដែរហាំ
ញ៉ុមនៅធ្វើការកូននៅទូចហាំ!!ញ៉ុមឃើញហើយ ញ៉ុមឃើញជួនកាលអ្នកបកប្រែហាំស្រួល
គេធ្វើការដូចថាគេនិយាយចិនហៅគេបកប្រែអីចឹងបានគេធ្វើ
គេថាគេស្រួលគ្រាន់តែដើរបកប្រែអោយគេ និយាយទៅស្រួលម៉ង
ហើយញ៉ុមញ៉ុមមានគំនិតខ្លួនឯងមួយ
ញ៉ុមគិតថាអើយបានសិនជាកូនអញបានធ្វើការបកប្រែនៅក្នុងរោងចក្រក៏អស់ចិត្តដែរ!!

កៈចាំ!!

ខៈ ថាបានប៉ុណ្ណឹងក៏អស់ចិត្តដែរ ហើយពេលហើយទៅពេលកូនញ៉ុមអាអូនវានៅទូចដែរ
នៅទូចដែរអោយរៀនសាលាចិនតាំងនៅពីទូចហ្នំ!! ដល់វារៀនអញ្ចឹងទៅ
កាលពេលវានៅរៀនហ្នឹងដូចវាយកសៀវភៅបោះចោលដែរហ្នឹង!!

កៈហ៊ឺៗ!!

ខៈ
ពេលរៀនរៀននៅសាលាចិនហ្នឹងរៀននៅនេះដល់ពេលហើយទៅញ៉ុមលែងគ្នាទៅញ៉ុមអោយកូនទៅញ៉ុមទុកកូននៅហ្នឹងផ្ទះហាំ!!ហើយឪក្មេកញ៉ុមហ្នឹងមកសុំ

មកមិនមែនសុំយកទៅដាច់ទេណាស់
គាត់ថាអញ្ចេកញ៉ុមហើយនឹងប្តីញ៉ុមហ្នឹងឈ្លោះគ្នាឈ្លោះទៅយើងរឿងចាស់ៗហា៎!!កុំបំផ្លាញអនាគតក្មេង!!

កៈហ៊ុៗ!!

ខៈ កុំបំផ្លាញអនាគតអាអូនហា៎!!គាត់ថាគាត់សុំយកចៅហ្នឹងទៅនៅជាមួយគាត់ គាត់អោយយកទៅរៀននៅសាលានោះ នៅនោះវាទំនើបជាងនៅសាលានៅឈូងលៀបហា៎!!

កៈចា៎!!

ខៈហើយបានទៅរៀននៅណោះទៅហើយបានរៀននៅសាលា!!សាលាអីគេ!!

កៈ ហោង តុង!!

ខៈ ហោង តុងគេហ្នឹង!!

កៈចា៎!!

ខៈ ហើយក៏បានរៀនភាសាចិនហ្នឹងរហូតមកដល់វាធំហ្នឹងទៅ
តែពីទូចអត់មានអាណាខ្ជិលដូចអាអូនញ៉ុមវាថា
ដូចថាវាខ្ជិលដែរតើ!!ថាវាស្អប់វាដែរតើមករៀនមកពីរៀនហ្នឹងមកដល់ផ្ទះអត់មានមើលមេរៀនអីទេណាស់ បោះសៀវភៅចោល!! បោះសៀវភៅចោលរហូត
ហើយអ្នកណាគេចង់អោយលុយវាទៅរៀន គេខឹងហា៎!!

កៈចា៎!!

ខៈ ដល់ពេលហើយដូចថាវាព្យាយាមហា៎ វាខំប្រឹងរៀនបានបានចេះវិញហ្នឹងហា៎!!

កៈ ហ្នឹងហើយ ឥឡូវគេភាសាអីក៏គេចេះដែរ!!

ខៈ ហ្នឹងហើយ!!

កៈ ចិនផង ថៃផង អង់គ្លេសផង
ហ៊ីសៀវព្រឹងចេះច្រើនណាស់មីងណាស់!!ពាក្យខ្លះញ៉ុមអត់សូវចេះទេ

តែសៀវព្រីងចេះហា៎!!ហ៊ីប៉ុនណាស់ ជំនាញម៉ង!!ឥឡូវហ្នឹងហា៎ ឥឡូវហ្នឹងវាខឹងញ៉ុមដែរតើ ដូចថាមកអញ្ចឹងបង្រៀនញ៉ុម ញ៉ុមរៀនលែងចូលហើយហ្នឹង បង្រៀនភាសាចិនដល់ញ៉ុមអញ្ចឹងញ៉ុមចង់ចេះអញ្ចឹងញ៉ុមទៅធ្វើការអញ្ចឹងញ៉ុមចង់ដឹងថាចិនវានិយាយអានេះម៉េចៗទៅហា៎!!ដល់ពេលវាបង្រៀនញ៉ុម ថាអានេះគេហៅអញ្ចេះអញ្ចេះបង្រៀនហើយសរសេរអក្សរខ្មែរអោយទៀតហ្នំ!!ដូចថាអានេះគេហៅម៉េចអញ្ចឹងហា៎ សរសេរអក្សរខ្មែរហើយបានដាក់បកអោយទៀត ហើយញ៉ុមអ់តចេះ!!

កៈចា៎!

ខៈ ដូចមកអញ្ចឹងវាបង្រៀនអញ្ចឹង បង្រៀនពីរបីម៉ាត់អញ្ចឹងអត់ចេះយូរៗ អូយធុញម៉ែឯងណាស់ មិនបាច់រៀនមិនបាច់អីទេ!!

កៈ បានមួយរៀងសមប្រកបដែរ បានមួយតែខ្លឹម!!ហ្នឹងហើយ អ្នកមីងអីចឹងចូលដល់ជីវិតអាពាហ៍ពិពាហ៍វិញម្តង អញ្ចឹងមិញបាននិយាយខ្លះៗពីជីវិតអាពាហ៍ពីពាហ៍ហើយប្តីអ្នកមីងមុននឹងលែងគ្នា ឥឡូវប្តីពីមុនមកគាត់ឈ្មោះអីគេវិញ?

ខៈ ឈ្មោះ វិត ភារត្ន័។

កៈ ចា៎វិត ភារត្ន័!!

ខៈចា៎!!

កៈចា៎!ចុះដល់ពេលសៀវព្រីងឈ្មោះអីគេឈ្មោះពេញ?

ខៈ វិត សុភា ។

កៈ វិត
សុភា!ហ្នំហ្នឹងហើយ!!អីចឹងអ្នកមីងពេលអ្នកមីងការ១៩៩៧ហី!!តាមបូកដកគុណចែកមក?

ខៈ ប្រហែលជាហ្នឹងហើយ !!

កៈចា៎!!

ខ៖ ព្រោះញ៉ុមអត់ចាំដែរហាំ!!វាយូរឆ្នាំហើយ!!

ក៖ ចាំដោយសារអ្នកមីងការ១៨ឆ្នាំ!!

ខ៖ចាំ!!

ក៖ អញ្ចឹង១៩៩៧ហ្នឹងហើយ!!មើលនិយាយប្រាប់ប្រវត្តិស្នេហាបន្តិចមើល!!

ខ៖ ស្នេហាពីដំបូងវា ដូចថាមានស្នេហាតែងតែភរម៉ែឪមែនអត់?ញ៉ុមភរម៉ែប៉ាញ៉ុម
អញ្ចឹងកាលពេលហ្នឹងគេថាអញ្ចេក គេដើរទៅលេងភ្នំតាម៉ៅអីវ៉ាន់ហាំ
គេមិនថាអញ្ចេកគេមិនមានឡាន
កាលសម័យហ្នឹងគេមានឡានគេទៅភ្នំតាម៉ៅគេយកម្នាក់ប៉ុន្មានពាន់អញ្ចឹងហាំ
ទាំងទៅទាំងមក!!

ក៖ ហ្នឹងហើយហើយស្គាល់ចាំ!!

ខ៖ ដល់ពេលហើយម៉ែសួរថាអញ្ចេកហ៊ី
ប៉ុន្តែសុទ្ធតែណាត់គ្នាហើយហើយណាស់គេណោះគេយកម៉ូតូមកយកហើយ ដូចថាប៉ាវា
ប៉ាវណោះគេអ្នកលក់ម៉ូតូនៅឃ្លាំងរំសេវហ្នំ!!

ក៖ ចាំ!!

ខ៖ គេរកស៊ីលក់ម៉ូតូនោះ ដល់ពេលម៉ែសួរថាហោហ្អែងទៅណា?ជិះឡានគេទៅហ្នឹង
ជិះឡានគេមកឈរចាំគេយកនៅមុខវត្តហ្នឹងហ្នំ!!

ក៖ចាំ!!

ខ៖ អញ្ចឹងទៅគេជិះឡានអញ្ចឹងទៅញ៉ុមថាអញ្ចេក
ជិះឡានក៏ជិះទៅទៅគេមានគេជិះមួយកំនរគ្នាដែរហាំ!!តាមពិតមកយក
ជិះម៉ូតូប៉ាអាភាហ្នឹងមកយកនៅគៀនឡានហើយហើយ
តែដល់ពេលចែដន្យស៊ីស្ទើរដល់ពេលទៅអញ្ចឹងទៅជាមួយគេជាមួយឯងតែដល់ពេលមកវិញម
កក្រោយគេ មកក្រោយឡាន!!

ក៖ ម៉េចទៅ?

ខ៖ ប៉ាស្ដីអោយ !!

ក៖ ប៉ាចាំមើលឡានទៀតហេ?

ខ៖ ហ្នឹងគាត់ស្ដីអោយថាញ៉ុមដើរអញ្ចឹងអីទៅណាស់!!

ក៖ចាំ!!

ខ៖ គាត់ស្ដីអោយ ស្ដីអោយអញ្ចឹងតែញ៉ុមអត់ចេះរៀងទេ!! នៅតែដើររហូតហ្នឹង!!

ក៖ ហ្នឹងហើយ ស្រលាញ់គ្នាប៉ុន្មានឆ្នាំបានការអ្នកមីង?

ខ៖កាលហ្នឹងស្រលាញ់គ្នាដូចរៀងអើរដូចរៀងយូរដែរ ដូចថា១ឆ្នាំ២ឆ្នាំចុះ
ហើយតែដូចថាពន្យាពេលយូរដោយសារអី !!ដោយសារឪក្មេកញ៉ុមនឹកឃើញថាក្មេងៗ!!

ក៖ហ្ហូ!!

ខ៖ គាត់ថាអញ្ចេកចាស់ៗគាត់និយាយថាអញ្ចឹង
តិចអញ្ចសង្ស័យវ៉ៃគ្នាដណ្ដើមគ្នាស៊ីបាយអញ្ចឹងទៅណាស់
នៅក្មេងៗអញ្ចឹងដូចគ្នាហាំ!!ថាអញ្ចឹង!!

ក៖ ខ្លាចអត់ដឹងអីអញ្ចឹងទៅ!!

ខ៖ ហ្នឹង!!ដល់ពេលទៅបានប៉ុន្មានឪក្មេកញ៉ុមណោះថាគាត់រកលុយបានអញ្ចឹងទៅណាស់
កាលកាលស្ដីញ៉ុម១ខែការហ្នឹង គ្រាន់តែស្ដីហើយធ្វើស្អីៗរៀបចំម៉ងហ្នឹង ការម៉ងហ្នឹង!!

ក៖ចាំ!!

ខ៖លឿនដែរហ្នឹង!!

ក៖ ជួបគ្នាដំបូងនៅណាវិញមីងបានចាប់ចិត្តស្រលាញ់គ្នា?

ខ៖ ដំបូងឪក្មេកញ៉ុមគាត់អ្នកម៉ៅការសំនង់ហាំ!!ម៉ៅនៅសាលាឈូងលៀបហ្នឹង!!

ក៖ចាំ!!

ខ៖ ហើយផ្ទះញ៉ុមលក់កាហ្វេលក់គុយទាវ លក់អីហ្នឹង លក់នំប៉័ងសាច់នំប៉័ងអីនោះ!!!!

ក៖ចាំ!!

ខ៖ ដល់ពេលហើយប្តីញ៉ុមហ្នឹងគេមិនអ្នកជាជាងធ្វើសំនង់ទេ គេអ្នកលក់ម៉ូតូគេមកលេងប៉ាគេឪគេធ្វើមេជាងនៅហ្នឹងហ្នំ!!មកលេងទៅដល់ហើយចូលផឹកកាហ្វេហាំ!!!

ក៖ចាំ!!

ខ៖ ចូលផឹកកាហ្វេកាលហ្នឹងមិនមានសម័យដាក់វីដេអូនបញ្ចាំង ។

ក៖ចាំ!!

ខ៖ វីដេអូបញ្ចាំង ដល់ហើយអញ្ចឹងឡូយណាស់
ហើយដល់ហើយចូលទៅហូបកាហ្វេចូលទៅហូបគុយទាវអីអញ្ចឹងទៅណាស់ក៏ឃើញណាស់!!

ក៖ហ៊ឺៗ!!

ខ៖ ឃើញទៅក៏ស្គាល់គ្នាអញ្ចឹងទៅ!!

ក៖ចាំ!!

ខ៖ បាទទំនាក់ទំនងទិញខោអាវទិញអីអោយញ៉ុមអញ្ចឹងទៅណាស់។

ក៖ ចាប់ផ្តើមស្រលាញ់ហើយហ្នឹងហោ?

ខ៖ ហ្នឹងហើយ!!

ក៖ ចាប់ផ្តើមដើរលេងជាមួយគ្នាភូតម៉ែភូតឪអញ្ចឹងទៅ!!

ខ៖ ភូតម៉ែភូតឪអញ្ចឹងទៅ!!!តែដល់ពេលអញ្ចេក
ដល់ពេលបែកគ្នាទៅដូចថាមានគំនិតគិតមួយថាគិតទៅសេចក្តីស្នេហាអត់មានគិតតែពីមុនមកជឿអត់?

ក៖ហ្នឹងហើយ!!

ខ៖ អត់មានគិតថាពីមុនមកធ្លាប់កំសត់អីណាគ្រប់បែបយ៉ាងហាំ!!

ក៖ ដល់ពេលត្រូវលែងគ្នាលែងផឹងៗម៉ង!!

ខ៖ លែងគ្នាលែងផឹងៗម៉ង!!

ក៖ ចាំ!!មីងមូលហេតុអីដែលលែងគ្នាជាមួយស្វាមីដែរ?

ខ៖ ដូចថាញ៉ុម ដូចថាទ្រាំលែងបានហើយ។

ក៖ វាម៉េចខ្លះទៅមីងបានវាដល់ទៅថ្នាក់ហ្នឹង??

ខ៖ ដូចថាពេលហ្នឹងយើងនិយាយគេអត់បានហ្ន៎ ដូចថាធម្មតាមនុស្សយើងហាំ គេមានអ្នកថ្មី តែយើងនិយាយអីក៏គេអត់ស្តាប់យើងដែរ!!ពេលញ៉ុមនិយាយអីចឹងគេមានកំហឹងជះមករហូត ជូនណាលញ៉ុមដាំបាយអញ្ចឹង ញ៉ុមមិនមែនដាក់អញ្ចឹង !គេធ្វើតុហាំ
គេធ្វើតុដាក់អោយរៀងខ្ពស់អញ្ចឹងទៅ
ដល់ពេលញ៉ុមដាក់ដាំអញ្ចឹងញ៉ុមដាំចង្ក្រានអុសញ៉ុមដាំទឹកហាំ!!ពេលញ៉ុមនិយាយអោយថាពេលចូលឆ្នាំអញ្ចឹងហា
ចូលឆ្នាំថ្ងៃដំបូងគេមិនដើរលេងអញ្ចឹងប្រុសៗគេជិះម៉ូតូដើរលេងទៅវាំធុងបាស់តាមភូមិអញ្ចឹង ហើយញ៉ុមថាអញ្ចេកញ៉ុមថាប៉ាអាភាកុំទៅអី ទៅធ្វើអីយើងវានេះហើយ
យើងមិនដូចក្មេងគេចេះតែដើរ ដូចថាយើងមានប្តីហើយ!!

ក៖ចាំ!!

ខ៖ទៅដើរលេងតាមភូមិសប្បាយអីអញ្ចឹងទៅណាស់
ដល់ពេលថាអោយមួយម៉ាត់ពីរម៉ាត់អញ្ចឹងខឹង អាកំសៀវហ្នឹងបើសិនជាកាំសៀវទឹកពុះហាំ
គឺញ៉ុមត្រូវរលាកហើយហ្នឹងអត់ទាន់នេះទេណាស់
ទឹមទឹកដូចថាវារៀងក្តៅបន្តិចៗហើយណាស់ធាត់មួយជើងកំពប់អស់រលីង !!

ក៖ ហើយជះត្រូវមីងដែរហេ?

ខ៖ ហ្នឹងជះត្រូវតែគ្រាន់តែទឹកហ្នឹងវាអត់ទាន់ក្តៅ!!ហ្នឹងនៅបានគ្រាន់តែរាងអ៊ុនៗទេណាស់!!

ក៖ចាំ!!

ខ៖ ចុះបើទឹកជិតពុះវាមិនរលាករលេសរលួយ!!

ក៖ គេឆេវឆាវខ្លាំងម៉ងមីងហោ?

ខ៖ គាត់ឆេវឆាវ!!ហ្នឹង!!

ក៖ តែដល់ពេលគាត់ស្រលាញ់គ្នាដំបូងអត់អញ្ចឹងទេមីងហី?

ខ៖ ហ្នឹង!!

ក៖ អីល្អទាំងអស់!!

ខ៖ ហ្នឹង អញ្ចឹងបើយើងអត់ដែលរស់នៅជាមួយគ្នាវាល្អហើយ!!

ក៖ហ្នឹងហើយ!!

ខ៖ កាលណាយើងរស់នៅជាមួយគ្នាយូរទៅធម្មតាតែមានស្រីចេះបែកគំនិតផ្សេងហា៎!!

ក៖ហ៊ឹៗ!!

ខ៖ បែកគំនិតធម្មតាចេះស្រលាញ់គ្នាណោះទៅ មើលឃើញប្រពន្ធខ្លួនឯងអាក្រក់រហូតហា៎!!

ក៖ចា៎!!

ខ៖ ធ្វើអីក៏ខុសដែរ ដល់ញ៉ុមទ្រាំមិនបានខ្ជិលហៅលែងគ្នាម៉ងទៅ!!

ក៖ ប៉ុន្មានឆ្នាំ ការហើយបានប៉ុន្មានឆ្នាំបានលែងគ្នា?

ខ៖ ការហើយអាអូន តាមមើលអាអូនបាន៦ឆ្នាំហើយបានលែងគ្នា!!

ក៖ចា៎!!

ខ៖ ថា៦ឆ្នាំចុះ!!

ក៖ ហើយម៉េចបានទៅជួបស្រីក្រោយហ្នឹងមីង?

ខ៖ ហ៊ីគេជួបមុន ដឹងថាគេជួបគ្នាមុនពីអង្គាល់ផងណាស់!!ញ៉ុមធម្មតាញ៉ុមធ្វើការដែរ
គេធ្វើការដែរទៅទៅ
ហើយមួយហ្នឹងធ្វើការរោងចក្រហើយធ្វើការរោងចក្រហើយមួយហ្នឹងធ្វើការនៅយ៉ុងវ៉ា
កាលហ្នឹងយ៉ុងវ៉ាគេមានដើរពីរវេនហាំ មានវេនយប់មានវេនថ្ងៃហើយមួយហ្នឹងធ្វើការវេនយប់
ហើយពេលថ្ងៃអញ្ចឹងធម្មតាគេផឹកស៊ី ទៅផឹកស៊ីនៅកន្លែងក្រោយវត្តព្រៃកសំរោងយើង
មិនមានផ្ទះលក់ត្នោតជូរ!!

ក៖ ចាំ!!ស្គាល់ហើយ!!

ខ៖ ហ្នឹង!ហើយមួយហ្នឹងឧស្សាហ៍ទៅលក់ ឧស្សាហ៍ជួយលក់នៅកន្លែងលក់ត្នោតជូហ្នឹងហាំ!!
ដល់ពេលទៅ ណោះឧស្សាហ៍ទៅផឹកត្នោតជូរបានស្គាល់បានអីគ្នាទៅ
ដល់ពេលមកផ្ទះអញ្ចឹងញ៉ុមនិយាយអីបន្តិចបន្តួចគេខឹងទូង
ខឹងញ៉ុមប្រាប់ខឹងស្មើរម៉ាន់ក៏ដោយអោយតែខឹងញ៉ុមអូសម៉ូតូចេញទាំងយប់!!

ក៖ហ៊ឺ!!

ខ៖ ខឹងថ្មើរម៉ាន់ម៉ូតូទៅហើយ ស្មើម៉ាន់ក៏ទៅដែរ!!

ក៖ ទៅរកស្រី!!

ខ៖ ចាំ!!វេចបង្វិចខោអាវទៅម៉ង!!ខឹងគឺដាក់ច្រកខោអាវទៅម៉ង!!

ក៖ ចំសាហាវណាស់អ៊ីចឹងហេ?

ខ៖ ហ្នឹង!!

ក៖ មីងទ្រាំប៉ុន្មានឆ្នាំបានសុខចិត្តលែងម៉ង?

ខ៖ ញ៉ុមទ្រាំយូរដែរហ្នឹង
ដល់ពេលហើយដល់ពេលញ៉ុមទ្រាំយូរដល់ពេលញ៉ុមគ្រាន់តែថាអត់ដឹងថាគេមានស្រីទេ!!មក
គ្រាន់តែដឹងថាមកវាមានឈ្លោះគ្នាមួយខែបើមាន៥០ថ្ងៃឈ្លោះគ្នា៥០ថ្ងៃ!!អត់ស្រូវគ្នាសោះហាំ!!
ធម្មតាមនុស្សយើងតែរស់នៅជាមួយគ្នាអត់ត្រូវគ្នាមានអារម្មណ៍ថាពីបាកចិត្តណាស់
ទៅធ្វើការអារម្មណ៍ញ៉ុមអត់ស្ងប់ទេ!!

កៈ តែចាប់ផ្ដើមមានស្រីហើយមីងណោះតែយើងអត់ដឹងមីងណោះ?

ខៈចាំ!!ហ្នឹង
ញ៉ុមដឹងទឹមឮមួយនោះឮផ្ទះនៅជិតវត្តហ្នុំ!!ទល់មុខវត្តផ្ទះលក់ចាប់ហួយហ្នឹងគេធ្វើការយ៉ុងវ៉ាវេនយប់ដែរគេប្រាប់ញ៉ុមតើ ដូចថាគេឃើញ គេហៅបង
បងឃើញប្ដីបងឯងឃើញឱបគេនៅធ្វើការផ្នែកនេះផ្នែកនោះអញ្ចឹងណាស់
ដល់ហើយទៅញ៉ុមមុនដំបូងញ៉ុមថាដូចថាក្នុងចិត្តខ្លួនឯងមិនមែនថាអត់ជឿគេទេណាស់
ជឿមួយហ្នឹងថាបងឯងចង់ដឹងបងឯងចាំទៅជាមួយញ៉ុមក៏បានដែរ!!ហើយញ៉ុមទៅហាំ
ញ៉ុមទៅញ៉ុមទៅឃើញតើ!ឃើញហើយម្នាក់ហ្នឹងញ៉ុមទៅឃើញហើយញ៉ុមទៅនឹកឃើញថាអញ្ចេកញ៉ុមក៏ធ្លាប់ធ្វើការដែរ ធ្វើការអ្នកធ្វើការជាមួយញ៉ុមអញ្ចឹងណាស់!!
គេមានដូចថាប្រពន្ធធ្វើការហ្នឹងមីស្រីប្ដីហ្នឹងវាធ្វើការហ្នឹងជាមួយគ្នាដល់ពេលដឹងទៅវាឈ្លោះគ្នានៅក្នុងរោងចក្រ ឈ្លោះគ្នាហ្នឹង ដល់ពេលអញ្ចឹងមីហ្នឹងរឹតតែឌឺរឹតតែខ្លាំង
រឹតតែផ្ដើនខ្លាំងដល់ហើយញ៉ុមនឹកឃើញថាអញ្ចឹង
មានគំរូនៅក្នុងរោងចក្រហ្នឹងមួយហើយណាស់
ហើយញ៉ុមនឹងធ្វើល្អដាក់អ្នកហ្នឹងពេលទៅយើងនិយាយស្រួលទេណាស់ថាហ៊ីកុំទាក់ទងប្ដីញ៉ុមរបស់មានម្ចាស់ហើយអីអញ្ចឹងហាំ!!
ញ៉ុមនិយាយអញ្ចឹងហាំនិយាយជាមួយគេស្រួលហាំ!!តែទីបញ្ចប់គេនៅតែអញ្ចឹង
គេអើអើរជាមួយញ៉ុមអញ្ចឹងមែនតែគេអត់គោរពពាក្យសន្យាជាមួយផងហ្នឹង។

កៈ ទៅយកប្ដីយើងទៅ?

ខៈ ហ្នឹង!!

កៈ ហើយឥឡូវយកម្នាក់ស្រីហ្នឹងប៉ុន្មានឆ្នាំហើយមីងណោះ?

ខៈ យកយូរហើយយូរឆ្នាំហើយដល់ឥឡូវ!!

កៈ តាំងពីបែកគ្នាមក?

ខៈ ហ្នឹងតាំងពីបែកគ្នាយកមីមួយហ្នឹងរហូត មួយហ្នឹងមេម៉ាយកូនមួយដែរ!!

កៈ ហោចង់ចូលឡើង១០ ២០ឆ្នាំឥលូវហើយនេះ!!

ខ៖ ហ្នឹង!!នៅជាមួយគ្នារាល់ថ្ងៃហ្នឹង!!

ក៖ ចាំ១០ឆ្នាំជិត២០ហ្នឹង!!

ខ៖ តែឥឡូវដូចថាជាគេ ដូចថាឥលូវញ៉ុមលែងខឹងហើយតើ!!

ក៖ចាំ!!

ខ៖ ថ្ងៃមុនដូចថាគេឃើញញ៉ុមគេហៅអញ្ចឹងហាំ!!មុនដំបូងគេអត់ហ៊ានហៅញ៉ុមទេ
ដាក់ទឹកមុខរហូតហ្នឹង
តែដល់ពេលឃើញញ៉ុមឧស្សាហ៍ទៅហើយដល់ពេលឃើញញ៉ុមអត់ប្រកាន់គេ
ឈប់ប្រកាន់ឈប់ខឹងគេ ពេលមុនញ៉ុមដូចស្រលាញ់ដល់ឥឡូវញ៉ុម!!

ក៖ ណាយហើយ!!

ខ៖
ណាយហើយហាំ!!លែងស្រលាញ់យើងទៅខឹងគេអីគេទៀតហាំ!!!!ដល់ហើយគេទាញចិត្តគេ
ថា
ពេលមុនប្រហែលជាញ៉ុមមានអំពើបាបច្រើនអញ្ចឹងទៅណាស់ឥលូវដូចថាពេលមុនញ៉ុមដូចមា
នជំពាក់កម្មជំពាក់ពៀរជាមួយអញ្ចឹងណាស់
មកសងអោយអស់ៗអញ្ចឹងទៅណាស់!!ទៅកាត់ចិត្តអញ្ចឹង!!

ក៖ ហើយអញ្ចឹងប្តីឥឡូវមានស្រីណាផ្សេងទៀតទេមីង?

ខ៖ ទៅនៅជាមួយគេណោះញ៉ុមអត់ដឹងដែរ តែឥឡូវលឺថាអាអូនថាប៉ាវាអត់អីទេ
អត់ដូចពេលមុនទេ!!តែឥលូវនិយាយរកញ៉ុមតើ!!ប្តីញ៉ុមនិយាយរកញ៉ុមហៅញ៉ុមតើ!!

ក៖ ហើយយកប្រពន្ធក្រោយមានការមានអីត្រឹមត្រូវទេ?

ខ៖ ប្រពន្ធក្រោយគេរៀប គេបានរៀបអីដែរណាស់!! គេនៅជាមួយគ្នា
ធម្មតាគេនៅជាមួយគ្នាហើយហើយបានគេរៀប
ដោយសារគេគិតថាគេមេម៉ាយគេអត់មានបញ្ហាអីគេទេ!!

ក៖ អូយញ៉ុមស្អប់ណាស់ អាមនុស្សស្រីយកប្តីគេអីវ៉ាន់!!ទោះមេម៉ាយហើយម៉េចក៏ដោយ!!

ខះចាំ!!

កះតែមានឈ្មោះយកប្តីគេហ្នឹង!!

ខះ ញុំមលើកមុននឹកឃើញតួចចិត្តខ្លួនឯង ញុំមហាំរក
កុំបានមីងអីនៅក្រោយឃាត់ញុំមហាំញុំមសម្លាប់ខ្លួនតើ!!

កះចំ!!

ខះ ញុំមដើរទៅក្រោយហ្នឹងហើយញុំមផឹកស្រាហ្មំ ហើយរាងស្រវឹងផងថារកសម្លាប់ខ្លួនតើ!!

កះ តែហេងវិញបានរកឈប់វិញ!!មីង!!

ខះហ្នឹងគាត់ គាត់ឃាត់ញុំម ដល់ពេលទៅគេនិយាយប្រាប់ពីរម៉ាត់ទៅគេឃាត់
ថាហ្អែងកុំធ្វើអញ្ចឹងហាំ!!

កះហ៊ឺៗ!!

ខះ ដល់ពេលគេនិយាយច្រើនណាស់ ដល់ពេលញុំមនឹកឃើញទាញចិត្តមកខ្ជិល
លែងដកចិត្តវិញ!!

កះ អត់អីទេ រឿងកន្លងហួសអស់រលីងហើយ!!
ហើយចុះពេលបែកគ្នាលែងគ្នាដាច់ជាមួយប្តីមកមានអ្នកណាគេស្រលាញ់សុំការអីអត់?

ខះអត់ទេ ពីមុនមាន ហើយញុំមនឹកឃើញថាខ្ជិលណាស់
ខ្ជិលម៉េច!ដោយសារឃើញមនុស្សប្រុសឥឡូវពិបាក!!

កះហ៊ឺៗ!!

ខះ ពិបាកណាស់!!

កះចាំ!!

ខះ ហើយណាមួយអ្នកខ្លះញុំមឃើញអ្នកមានប្តីមានប្រពន្ធតែប្តីមកអញ្ចឹងទៅជេរប្រពន្ធ
ប្រពន្ធមកពីធ្វើការអញ្ចឹងណាស់!!!កះហ៊ឺៗ!!ខះជេរអាខ្លួនឯងនៅផ្ទះអត់ធ្វើអីផងហ្នឹងហាំ!!ហើយ

ដល់ពេលប្រពន្ធមកផ្ទះក៏អត់ធ្វើបាយអោយគ្នាស៊ី
ញ៉ុមឃើញផ្ទះមួយនៅនោះនៅផ្ទះមើលតែកូនបន្តិចបន្តួចហើយប្រពន្ធមកពីធ្វើការធ្វើអោយ
អោយស៊ីហើយដេរទៀត ហើយពេលណាវាត្រូវផឹក
ផឹកជាមួយពួកម៉ាក់ចាននឆ្នាំងចោលគ្នាមកពីធ្វើការហើយលាងទៀត
ហើយញ៉ុមនឹកឃើញអញ្ចឹងពិបាកណាស់ មនុស្សប្រុសយ៉ាប់អញ្ចឹងណាស់!!

ក៖ យើងមករកស៊ីដែរ យកមកមិនស្រួលអាខ្លះផឹកទៀត!!

ខ៖ចាំ!!

ក៖ ផឹកហើយអាខ្លះមិនស្រួលហ្នឹង !!

ខ៖ ដេរយើងទៀត!!

ក៖ ធ្វើបាបយើងចាំយើងមកមានត្រូវដាំបាយធ្វើម្ហូបស្លរអីហ្នឹង
បើសិនជាប្តីជាប្រពន្ធតាំងពីយូរយារណាស់មកវាមិនអីទេណាស់
ដល់ធ្លាប់មានបទពិសោធន៍អញ្ចឹងហើយទៅយកអញ្ចឹងទៀតវាធ្វើអោយពីបាកខ្លួនទៅអញ្ចឹង
ទៅណាស់!!

ខ៖ ហើយនៅហ្នឹងដែរមានគេនៅហ្នឹងដែរមានគេចង់បានដែរតែប្អូនយើងទឹមតែ៣២ ៣៣
តែយើងខ្ជិលយក ខ្ជិលយកអាម៉េច! ខ្ជិលណាស់ យើងបងគេយើងហៅគេឪ
ហៅគេប្អូនធ្វើប្តីម៉េចហើយណាមួយបើគេស្រួលអត់អី
ចុះបើមកគេពៃលោរដាក់យើងយើងរឹតតែឈឺចាប់ថែមទៀត ហើយមាត់មនុស្សហាំជឿហ្ន៎
បើយើងយកប្តីក្រោយល្អហើយមានបានហាំអាហ្នឹងគេសរសើរ
ហើយបើយកក្រោយហើយលើសទៀតបឹមមិនដឹងមីហ្នឹងចរិកម៉េចបានជាប់
!ញ៉ុមធ្លាប់ឮហាំ!!ញ៉ុមឮផ្ទាល់ត្រចៀកញ៉ុម យើងមានប្តីមួយប្តីពីរ យើងអត់ស្រួលទេ!!

ក៖ ហ៊ីពិបាកណាស់!!មនុស្សចាំតែនិយាយអ៊ីចឹងណាស់!!

ខ៖ចាំ!!ហ្នឹង!

ក៖ចាំ!!

ខ៖ ហើយញុំមនិយាយទៅបានអាអូនញុំមអញ្ចឹងទៅវាមានការងារធ្វើអញ្ចឹងទៅញុំម ឥលូវក៏ញុំមលែងសូវខ្វាយខ្វល់អីដែរ ។

ក៖ កូនបានដល់ត្រើយហើយ !!

ខ៖ហ្នឹង!!

ក៖ នៅមានប្រពន្ធមួយតង់ទៀត!!

ខ៖ ហ្នឹង!!

ក៖ មីងមើលទៅចាត់ការសៀវព្រីងអោយយកប្រពន្ធអោយបានណាស់មីង ញុំមតែងតែប្រាប់សៀវព្រីងរហូត ថាសៀវព្រីងការប្រពន្ធហិ!!ចេះតែនិយាយគ្នាតែនិយយាគ្នាជាមួយសៀវព្រីងត្រូវគ្នាណាស់!!!

ខ៖ចាំ!!

ក៖ ពេលការហើយមានកូនតែសៀវព្រីងមួយតើមីងហេ?

ខ៖ ហ្នឹងហើយមានតែមួយហ្នឹង។

ក៖ ចាំ!!សង្ឃឹមថ្ងៃក្រោយសង្ឃឹមលើគាត់ហើយមីងណេះ?

ខ៖ ហ្នឹងសង្ឃឹមមួយហ្នឹង តែដឹងគេម៉េចទេ!!

ក៖ ញុំមមើលទៅគិតថាគាត់ស្រលាញ់មីងហើយគិតគូរមីងច្រើនអញ្ចឹងហើយស្និតស្នាលជាមួយមីងច្រើន!!អអញ្ចឹងមីងដល់ពេលសៀវព្រីងអញ្ចឹងមីងផ្គត់ផ្គង់អោយឬក៏សៀវព្រីងជាអ្នកជួយវិញឥឡូវ?

ខ៖ អត់ទេឥលូវនៅតែផ្តល់អោយតែឥឡូវមួយរយៈនេះអត់ទេដោយសារឥឡូវអីគេដោយសារសារហ្នឹងថ្លៃសាលាប៉ាវាអ្នកបង់ហាំ!!តែឥឡូវមានការងារធ្វើហើយមានការងារធ្វើ មួយរយៈមុនវាធ្វើការដែរ វាធ្វើយប់ហើយមើលទៅកូនវាពិបាកពេកណាស់!!

ក៖ហ៊ឺៗ!!

ខ៖ញុំមថាមិនបាច់ធ្វើទេញុំមថាអោយប៉ាវាហ្នឹងអោយប៉ាវា
អោយជួយបង់ថ្លៃសាលាអញ្ចឹងទៅណាស់!!ឆ្នាំហ្នឹងឥឡូវវាថាប៉ាវាជាអ្នកបង់
ហើយឥឡូវគេមានគ្រូអាចប្តូរសាលាហើយណាស់
គ្រូមុនបង្រៀនថ្ងៃហើយឥឡូវបង្រៀនយប់ហើយ អត់សូវ ឥឡូវធ្វើការថ្ងៃ
ឥឡូវហ្នឹងវាអាចមានលទ្ធភាពរកបានចាយខ្លួនឯងហើយនឹងបង់ថ្លៃសាលាខ្លួនឯងហើយ!!

ក៖ ហ្នឹងហើយអញ្ចឹងល្អហើយ!!

ខ៖ យើងអត់ចាំបាច់ផ្គត់ផ្គង់វាទៀតទេ!!អញ្ចឹងហាំ!!

ក៖ អញ្ចឹងធូរហើយ។

ខ៖ ហ្នឹងហើយធូរ!!

ក៖
ចាំល្អណាស់អញ្ចឹង!!មីងសំរាប់អ្នកមីងហាំពេលវេលាណាដែលអ្នកមីងពិបាកជាងគេបំផុតវិញ
ទៅ?

ខ៖ ហេញុំមពិបាកបំផុតមួយរយៈមុននិយាយទៅយូរឆ្នាំមកហើយ
និយាយទៅតាំងពីញុំមពេលពិបាកចិត្តលែងគ្នាហើយក៏ដោយក៏អារម្មណ៍ញុំមក៏អត់ទាន់លែង
ស្ងប់ដែរ!!នៅថាពេលអារម្មណ៍យើងថាពេលស្រាយើងហូបខ្លះអីចឹងទៅណាស់
ចង់តែផឹកអញ្ចឹងទៅណាស់រំសាយ ដូចថាបំភ្លេចហាំ!!

ក៖ចាំ!!

ខ៖ញុំមហាំដូចល្ងាចញុំមផឹកអញ្ចឹង ញុំមឆ្ងល់ដល់ហើយញុំមភ្លេចទាំងអស់!!
អ់តមាននឹកឃើញទេ ពេលស្រវឹងហើយដេកលក់ហើយ ។

ក៖ហ៊ឺៗ!!

ខ៖ ហើយកាលហ្នឹងញុំមធ្វើបាបអាអូនតើ!!វានៅរៀងជំទង់ដែរហាំ ផឹករហូត
ហើយចាំមើលពេលកាលហ្នឹងកាលនៅចាក់អង្រែហ្វូ!!ជិះកង់៣គេហាំ!!

កះចាំ! រំលឹករឿងអតីតកាលអ្នកមីងក្តុកក្តួល!!អត់អីទេ!!

ខះ ហ្នឹងជិះកង់៣គេដាក់ខែហើយអាភាវាចាំផ្លូវហ្នំ!!

កះចាំ!!

ខះ ចាំផ្លូវទៅ ម៉ែចូលផឹកស្រារួចហើយហើយ!!

កះអានិតកូនមីងហេ?

ខះ ផឹកស្រាមកវិញស្រវឹងខឹងកូនទៀត!!ជួនកាលជេរវាសុទ្ធតែពូជហ្អែងអញ្ជឹងហិ!!

កះហ៊ឺៗ!!

ខះខឹងតើ!!

កះ ចាំហ្នឹងហើយ
ដោយសារញ៉ុមយល់ពីអារម្មណ៍ឈឺចាប់របស់អ្នកមីងដោយសារទឹមតែស្រាយពីកំហឹងជាមួយប្តីអ៊ីចឹងទៅណាស់!!ហើយកំពុងនៅងំនៅឡើយទេ!!ញ៉ុមពិតតែអត់មានប្តីអត់មានអីផងពេលខ្លះមានសង្សារបែកគ្នាជាមួយសង្សារឈឺចាប់ណាស់មីងណាស់!!អត់ស្រួលទេ!!

ខះ ហើយនេះហាំ ចេះតែវ៉ៃអាភាចេះតែវ៉ៃកូនវ៉ៃអីហើយញ៉ុមធ្វើបាបវាណាស់!!កះចាំ!!ខះ
ដល់ពេលឥឡូវឃើញស្តាយណាស់
ដូចថាខឹងបុគ្គលផ្សេងសោះយកក្មេងយកមកធ្វើអញ្ជឹង!!!កះចចាំ!!ខះតែអត់សួរយូរណាប៉ុន្មានដែរណាមីងហេ?

ខះ
អត់សួរយូរទេតែគ្រាន់តែថាញ៉ុមមិនមែនចេះតែខឹងរហូតទេណាស់ពេលណាអញ្ចឹងទៅញ៉ុមក៏ស្រលាញ់កូនអញ្ជឹងទៅ ពេលមកអញ្ជឹងកាលញ៉ុមទៅធ្វើការញ៉ុមប្រាប់ថា
អាអូនយ្សូរទឹកដាក់អាង
ចាំមកវិញម៉ាក់អោយ១០០០ឬក៏៥០០អីអញ្ជឹងទៅណាស់!!អាងទូចនៅក្នុងបង្គន់ហ្នឹងវាចេះតែយួរទៅមកវិញពេញអ៊ីចឹងអោយលុយកូនទៅណាស់!!

កះហ៊ឺៗចាំ!!

ខ៖ តែគ្រាន់តែថាអញ្ចេកពេលញ៉ុមផឹកអញ្ចឹង
ពេលញ៉ុមអត់ផឹកអញ្ចឹងញ៉ុមនិយាយអីដឹងខុសត្រូវណាស់។

ក៖ចាំ!

ខ៖ស្រលាញ់កូនណាស់តែផឹកស្រា តែកូននិយាយអីតិច ប្រើវា
វារឹងអីអញ្ចឹងណាស់មានអារម្មណ៍មួយថារឹតតែខឹង
ផឹកស្រាអីតិចតួចដឹងថាកូនហ្នឹងដឹតតែស្ដីអោយម៉ង!!

ក៖ម៉ង!!អញ្ចឹងអ្នកមីង អ៊ីចឹងសង្ឃឹមលើភាទៅថ្ងៃក្រោយហើយហោ?

ខ៖ ហ្នឹង !!

ក៖អញ្ចឹងបានស្គាល់ដំណឹងល្អតាមរយៈកូនដែរតើមីងហោ?

ខ៖ហ្នឹងហើយ។

ក៖អ៊ីចឹងជីវិតអ្នកមីងត្រូវបានកែប្រែច្រើនមែនទែន!!

ខ៖ហ្នឹង!!

ក៖ចាំអ៊ីចឹងលែងបានផឹកស្រា!!

ខ៖ ទឹមបានកែប្រែមួយឆ្នាំហ្នឹង!!

ក៖ចាំ!!

ខ៖ថាមួយឆ្នាំអត់ដល់មួយឆ្នាំផង។

ក៖ចាំ!!អ៊ីចឹងសាច់ឈាមក៏ស្រស់ថ្លាតាមហ្នឹងដែរណាស់!!

ខ៖
តាំងពីថាតាំងពីញ៉ុមនៅផឹកហ្នូ!!ញ៉ុមប្រាប់ទៅធ្វើការមួយខែបានមកវិញទប់តែញ៉ុមផឹកហើយ
អោយកូនតិចតួចហ្នឹង អត់មានសល់សោះ!!

ក៖ ចាំ!!

ខ៖
បានមកដឹងតែមួយខែមួយខែបានមកអស់ៗហើយកាលពីមុនញ៉ុមមមានលុយចងការអោយគេ
ណាស់ត្បិតញ៉ុមថាបែកគ្នាតែញ៉ុមធ្វើទ្រុងជ្រូកក្រោយញ៉ុមចិញ្ចឹមជ្រូកទៀតណាស់!!ធ្វើការមកវិ
ញចិញ្ចឹមជ្រូកហាន់ត្រកួនហាន់អីអញ្ចឹងទៅបបរបាយជ្រូកអញ្ចឹងទៅណាស់
ដល់ពេលនេះទៅលក់ជ្រូកអីចឹងញ៉ុមចងការទាស់តែគេបោកញ៉ុមតើ!!ដូចថាញ៉ុមចេះតែអានិត
គេអញ្ចឹងទៅណាស់!!

ក៖ចាំ!!

ខ៖ ដូចថាធម្មតាទេមនុស្សយើងធ្លាប់តែពិបាកហាំ
ដល់ពេលមានអញ្ចឹងទៅទារគេគេថាអត់អញ្ចឹង ញ៉ុមមិនដឹងទៅថាម៉េចគេ!!!ហើយទៅធ្វើការ
ទៅធ្វើការនេះផងហើយដាក់លុយអោយគេអញ្ចឹងទៅបានមកអោយកូនចាយអញ្ចឹងទៅណា
ស់ហើយពេលចេញមកជិះកង់បីដាក់ខែអោយគេ
ចេញមកទិញអីទិញលតឆារទុកច្រកថង់ទុកអោយកូនអញ្ចឹងទៅណាស់ហើយកូននៅចាំថ្នល់
ហ្នំ!!

ក៖ ចាំនៅចាំផ្លូវម៉ែ!!

ខ៖ ហ្នឹងហើយ!!

ក៖ ភាគច្រើននៅពីក្មេងច្រើនតែអីចឹងមីងណោះ?

ខ៖ នៅអង្គុយនៅហ្នឹង នៅផ្ទះគេនៅហ្នឹង
គេលក់អីវ៉ាន់ចាប់ហ្វ៊ុយដែរនៅហ្នឹងហាំ!!ពេលញ៉ុមឈប់កង់បីមកញ៉ុមចូលមកផ្ទះហ្នឹងហើយ
ផ្ទះហ្នឹងគេលក់ស្រាលក់អីហើយស្រេចចូលហើយផឹកស្រាមួយកែវហើយបានដើរមកផ្ទះ
ផឹកស្រាហើយច្រកទៀតច្រកហាំ!!

ក៖ចាំ!!

ខ៖ ផឹកមួយពែងហើយបណ្ដើរកូនដើរមកអោយកូនស៊ីហើយអីហើយ
អាហ្នឹងអត់ទាន់ស្រវឹងទេណាស់!!ដល់ពេលអញ្ចឹងទៅដល់ពេលចុងក្រោយបានច្រកមកផ្ទះដឹង
តែស្រវឹងហើយ!!

កៈ អញ្ចឹងអ្នកមីងដោយសារអ្នកមីងកើតនៅក្នុងឆ្នាំដែលបែកប៉ុល ពតហើយណោះមីងណោះ?

ខៈ បែកហើយហើយ!!

កៈអញ្ចឹងមីងបានធ្លាប់ឮអីគេខ្លះពីជំនាន់ប៉ូល
ពតទោះពេលហ្នឹងអ្នកមីងអត់ទាន់អីក៏ដោយគ្រាន់តែឮអញ្ចឹងហាំម៉េចដែរ?

ខៈ
លឺគ្រាន់តែលឺម៉ែនិយាយអីចឹងថាជំនាន់ហ្នឹងពិបាកណាស់ញ៉ុមថាបើសិនជាញ៉ុមកើតទាន់ជំនាន់ហ្នឹងពិបាកប៉ុណ្ណាទេពេលហ្នឹងហាំ!!

កៈ មីងក្រោយតែបន្តិចទេណាស់ !

ខៈហ្នឹងំ!!

កៈ
ក្រោយប្រហែលជាតែមួយខែអីវ៉ាន់ទេ!!អូយម៉េចទៅមីងម្ដាយប្រាប់អីគេទៀតពេលជំនាន់សង្គ្រាមទៀតទៅ?

ខៈម៉ែញ៉ុមញ៉ុមអត់នេះទេគ្រាន់តែគាត់និយាយថារាល់ថ្ងៃគាត់នីយាយថាពួកញ៉ុមនិយាយអីដាក់ប្អូនអញ្ចឹងហាំ គាត់ថាអញ្ចេកហ៊ីពួកឯងនេះបើកើតជំនាន់អាពតងាប់អស់ហើយអញ្ចឹងហាំ!!

កៈចាំ!!

ខៈ គាត់គ្រាន់តែនិយាយអីចឹងអត់មាននិយាយអីទៀតអីផ្សេងទៀតទេ!!

កៈ ចាំ!!អីចឹងហើយការរងទុក្ខវេទនាអីក៏អត់បាននិយាយមកដែរមែនទេ?

ខៈ ហ្នឹងគ្រាន់តែយើងមើលទូរទស្សន៍៧មករាអីគេចាក់ទៅមើលឃើញគេដកក្រចកដៃដកអីញ៉ុមថាហ៊ីពេលមុនសាហាវណាស់ បើសិនជាកើតនៅលើយើង
យើងមើលឃើញគេដកក្រចកដៃក្រចកអីមានអារម្មណ៍ថា!!

កៈមានគេចាក់អញ្ចឹងដែរមីងហេ?

ខៈ មានតើ!!

កៈ ញុំមដឹងតែពេលគេវ៉ៃគ្នាវ៉ៃអីប៉ុន្តែអារឿងដកក្រចកញុំមអត់ដែលឃើញ!!

ខៈ ដកក្រចកឃើញតើពេល៧មករាគេចាក់អោយមើលអោយយើងមើលតើ!!

កៈអូ្យអាក្រក់ណាស់!!

ខៈ តាមទូរទស្សន៍ហ្នឹង!!!

កៈ ញុំមថាមនុស្សយើងសាហាវណាស់ពេលនៅរស់គេយក
យកកាចាប់អីយកមកដកអីចឹងហាំសាហាវប៉ុណ្ណាទេ
ឈឺណាស់ទំរាំតែយើងកាត់សាច់ដាច់តែម៉ាបន្តិចយើងឈឺ !!អីចឹងបានថាហ្នឹងហាំ!!

កៈចាំ!!

ខៈអញ្ចឹងបានថាពិបាកណាស់!!មើលទៅយើងមើលតាមរូបភាពទេណាស់មិនដែលឃើញរឿងពិតទេ!!

កៈចា!!

ខៈតែថាពិបាកណាស់!!

កៈហ្នឹងហើយមីងប្រហែលជាអញ្ចេកយើងពេលមានការឈឺចាប់អីអីចឹងណាស់ប្រហែលជាយកអាពេលវេលាណាពិបាកយកមកគិតវិញថាគេពិបាកជាងយើងវិញទៀត
ឯងទឹមតែពិបាកប៉ុននេះយើងនៅមានក្តីសង្ឃឹមមែនទេមីង?

ខៈ ហ្នឹងហើយ ។

កៈ
អីចឹងប្រៀបធៀបអាការលំបាកនោះយកមកប្រៀបធៀបលើខ្លួនយើងវិញអញ្ចឹងយើងអាចតស៊ូបាន!!ហ្នឹងហើយយើងអាចនិយាយបានថាមានគេពិបាកជាងយើងទៀត
ប៉ុណ្ណឹងយើងពីបាកអីយើងមានក្តីសង្ឃឹមតទៅមុខទៀតទៅមីងណោះ?

ខៈ ចាំ!!

កៈ ប្រសើរសំរាប់ក្នុងជីវិតចាំ!!

ខ៖
ហើយស៊ីស្ទើរឯងដឹងទេកាលញ៉ុមនិយាយពីញ៉ុមផឹកហាំញ៉ុមប្រាប់ទៅលុយដើរតែសៀតគ្រប់កន្លែងអ់តមានម្ចាស់ការលើខ្លួនឯងទេណាស់!!

ក៖ហ៊ឺៗ!!

ខ៖ មកអញ្ជឹងទៅលុយចេះតែដើរសៀតដល់ពេលអស់ដើររកអញ្ជឹងទៅ
ពេលរកលុយចាយអ៊ីចឹងមិនដឹងរកលុយនៅណារកលុយអត់ឃើញទេ!!

ក៖ហ៊ឺ!!

ខ៖ ជួនកាលដើរអញ្ជឹងក៏ជ្រុះលុយបាត់អញ្ជឹងទៅណាស់!!

ក៖ ចុះស្រវឹងអីវ៉ាន់ហ្នំអត់ដឹង!!

ខ៖ ស្រវឹងអ៊ីចឹងនៅផ្ទះទៅ
ជួនកាលម៉ែគាត់ឃើញញ៉ុមស្រវឹងញ៉ុមអីអញ្ជឹងគាត់បិទទ្វារបិតអីអោយអញ្ជឹងទៅ!!
ជួនកាលថ្កក់សោរ ថ្កក់សោរអោយហើយខាងក្រោយញ៉ុមនៅតែក្នុងផ្ទះទៀត!!

ក៖ចាំ!!

ខ៖ អត់បានចេញទៅណាទេ
ដូចថាគាត់អត់បាននឹកឃើញខ្លាចគេដើរមកទ្វារចំហរទ្វារអីហ្នឹងហាំ!!ហ្នឹងហាចេះមួយរយៈហ្នឹងនៅជិតម៉ែចុះបើនៅឆ្ងាយពីម៉ែ!!

ក៖ខ្វេចអស់ហើយ!!

ខ៖ ដឹងខ្លួនញ៉ុមទៅដល់ណា!!ក៖ចាំ!!ខ៖
ហ្នឹងកាលហ្នឹងកូនទៅណោះហើយចាំមើលពិបាកមុនដំបូងមានកូននៅជាមួយអត់សូវអីទេណាស់ ដល់ហើយថាយកអាអូនទៅនៅណោះ
ទៅនៅណោះមានអារម្មណ៍ថានឹកកូនអើយនឹក!!

ក៖ អោយទៅនៅខាងប្ដីហ្នឹងហេ?

ខ៖ ចាំ!!មានអារម្មណ៍ថានឹកកូនមួយសារទៀតហើយណាស់!!

ក៖ចាំ!!

ខ៖ នឹកកូនដល់ពេលចេះគិតចេះតែស្មុគចេះតែគិត អោយតែល្ងាចឡើងផឹកហើយ
ទៅធ្វើការពេលថ្ងៃអត់អីទេ
ចេះតែប្រឡប់ៗភ្លេចទៅណាស់!!តែដល់ពេលមកផ្ទះញ៉ុមនឹកឃើញរហូត!!

ក៖ហ៊ីៗ!!

ខ៖
អោយទិញស្រាពេលផឹកទៅស្វាងទៅនឹកឃើញវិញដដែលហ្នឹងហោ!!តែដល់ពេលបានចូល!!

ក៖ប៉ុន្មានឆ្នាំមីងបាននេះ ?

ខ៖អូយញ៉ុមទឹមតែឥលូវទេ !!

ក៖អញ្ចឹងឈឺចិត្តមិនមែនតិចឆ្នាំទេអញ្ចឹង!!!

ខ៖ឈឺចិត្តយូរ ទឹមតែឥឡូវ
ណាមួយញ៉ុមនឹកឃើញថាឈឺចិត្តជាមួយប្ដីញ៉ុមនឹកឃើញថាអញ្ចេកកាលពីមុនហាំ
កាលពេលការហើយអីអញ្ចឹងណាស់ មើលទៅស្រលាញ់គ្នា
មើលក្ដីស្រលាញ់សូម្បីតែបោកខោអាវក៏ដោយជួយបោកទាំងអស់គ្នា
មុននឹងផ្ទះកាលពីមកនៅនេះហើយណាស់ក៏មិនទាន់ដល់វក់វីដល់ម្លឹងហ្នឹងដែរ!!
នៅជួយបោកខោអាវបោកអីអញ្ចឹងទៅណាស់
ចុះថ្ងៃអាទិត្យយើងសំរាកទាំងអស់គ្នាហើយគាត់ចេះតែជួយធ្វើ
ហាលខោអាវហើយបានទៅតាខ្មៅទៅណោះហាំ
ដល់ពេលបែកគ្នាមានអារម្មណ៍ថានឹកឃើញអនុស្សាវរីយ៍ពីមុនមកធម្មតាអាអ្នកគេទៅបាត់អត់
អីទេណាស់ អ្នកនៅបានឈឺចាប់។

ក៖ គេមានអ្នកនៅណោះលួងចិត្តអីវ៉ាន់អញ្ចឹងទៅណាស់!!

ខ៖ ហ្នឹងហើយ។

ក៖
ហើយចុះមីងពេលហ្នឹងដឹងហើយថាពិបាកដើម្បីរកប្ដីមួយទៀតតែពេលខ្លះក៏អាចមានអ្នកថ្មីផ្សេងមួយទៀតដើម្បីអើរលួងលោមចិត្តយើងប្រហែលជាគេប្រសើរជាពូអញ្ជឹងទៅណាស់!!

ខ៖អត់ទេញ៉ុមគ្រាន់តែថាមើលទៅយើងដូចថាខុសមួយហើយខុសមួយទៀតពិបាក!!

ក៖ញ៉ុមអត់ទេតែរនាបបាក់យករនាបជួសម៉ង!!

ខ៖ញ៉ុមអត់ទេចង់និយាយថាឥឡូវអាអូនវាស្រួលដែរណាស់ ហើយវាអត់ចេះខិលខូច
បើវានៅនេះក៏ខូចដែរ ក្មេងញ៉ុមជឿថាក្មេងប្រុសវាអត់ខ្លាចវាអត់សូវខ្លាចម្ដាយទេនេះ
ហើយនឹងបានវាចេះទៅនៅណោះហាំ!!ខ្លាចតាវាអីអញ្ជឹងទៅណាស់វាគ្រាន់តែខ្លាចទៅណោះវា សូម្បីតែខ្លួនវាផ្ទាល់វាថាដែរ វាថាម៉ាក់ហាញ៉ុមបើញ៉ុមនៅណោះវាខិលខូចច្រើនណាស់
អញ្ជឹងបានទៅនៅណោះទៅណាស់។

ក៖ ចាំ!!និយាយទៅមិនសូវជាឆ្ងាយពីគ្នាអីណាប៉ុន្មានទេមីងណោះ?

ខ៖ ចាំ!!ចង់!!

ក៖ មីងមានរឿងអីដែលចង់និយាយប្រាប់ទេ?

ខ៖ អត់ទេមានតែប៉ុណ្ណឹង!!

ក៖ ចុះម៉េចដែរដល់ពេលបានចូលព្រះវិហារហ្នឹងមកបានអ្នកមីងបានធូរចិត្តអញ្ជឹងទៅ?

ខ៖ ញ៉ុមបានអាអូនណែនាំប៉ុណ្ណឹង
ហើយស៊ីស្មើរចិតហើយនឹងស៊ីស្មើរសុខហាំ!!បានកែប្រែបានដល់ថ្ងៃហ្នឹងហិ!!ញ៉ុមនឹកគុណគាត់អត់ភ្លេចទេ!!ហើយញ៉ុមហាំញ៉ុមតេទៅស៊ីស្មើរសុខដែរតើ!!តែអត់មានទូរសព្ទ័គាត់។

ក៖ អត់ទាន់ដោយសារអត់ទាន់ចប់បេសកម្មអីចឹងពិបាក !!

ខ៖ ហ្នឹង!!

ក៖ដល់ពេលគាត់ចប់អញ្ជឹងទៅមានហ្វេសប៊ុកមានអីអញ្ជឹងទៅអាចបានហើយ!!

ខ៖ ហ្នឹងហើយ ចាំមើលគាត់កាលពេលមកញ៉ុមសរសើរចិត្តគាត់ណាស់
មកហាំញ៉ុមប្រាប់ភ្លៀងហាំភ្លាកៗៗហើយអាកាលហ្នឹងហាំញ៉ុមអត់ទាន់
អត់ទាន់ឈប់ផឹកទេណាស់ ពេលភ្លៀងទេណាស់ញ៉ុមស្រវឹងហាំញ៉ុមដេក
ដេកនៅក្នុងអង្រឹងហាំ!!ម៉ែញ៉ុមដាស់ញ៉ុមអើយដាស់
ហើយដឹងថាណាត់ជាមួយស៊ីស្ទើរសុខហើយហ្នឹងហាំតែនៅតែអញ្ចឹងទៀតញ៉ុមណាស់ម៉ែញ៉ុម
ដាស់ហើយដល់ហើយដូចថាវាមិនស្រវឹងខ្លាំងណាស់ណាទេណាស់
ដឹងថាញ៉ុមផឹកហើយតែញ៉ុមវាអត់ស្រវឹងខ្លាំងណាស់ញ៉ុមទៅយកស៊ីស្ទើរសុខនៅណោះទៅដ
ល់ផ្លូវថ្នល់ហាំ!ហើយភ្លៀងឡើងក្រាំកៗៗស៊ីស្ទើរសុខញ៉ុមប្រាប់ហាំ
ថាពាក់អាវភ្លៀងហាំ!!ញ៉ុមនឹកឃើញគ្រាកំសត់គាត់ណាស់
នឹកឃើញហើយតែស៊ីស្ទើរញ៉ុមឆ្ងល់ស៊ីស្ទើរឥឡូវអត់ដូចស៊ីស្ទើរសុខស៊ីស្ទើរចិតទេ
ហើយមើលដូចស៊ីស្ទើរមកថ្មីលែងមកសួរសុខទុក្ខញ៉ុមយូរហើយស៊ីស្ទើរខ្មែរយើងហាំ!!ក៖ចាំ!!
ខ៖លែងគាត់អត់ធាក់ដូចស៊ីស្ទើរសុខស៊ីស្ទើរចិតទេ។

ក៖ ពេលខ្លះស្ថានភាពខុសគ្នាហ្នំអ្នកមីងដោយសារពេលខ្លះគាត់ហត់ឬមួយគាត់ឈឺអីចឹង
ពេលខ្លះអ្នកខ្លះធ្វើការខ្លាំងអ្នកខ្លះធ្វើការតិច តាមដោយមនុស្សអីចឹងទៅណាស់មីងណាស់!!

ខ៖ញ៉ុមសរសើរស៊ីស្ទើរសុខហើយនឹងស៊ីស្ទើរចិតណាស់
មកផ្ទះញ៉ុមភ្លៀងរអិលដួសរយ៉ាស់ហាក្បាលជង្គង់ហាំ!
ហ្នឹងហើយគាត់ថាអត់អីអត់អីទេហើយដល់ពេលយប់ដល់ពេលចេញពីផ្ទះញ៉ុមទៅអើយញ៉ុម
ថាស៊ីស្ទើរអើយឯងឆឹតហើយនេះ ស៊ីស្ទើរថាអត់អីទេញ៉ុមបំរើផ្ទះ
គាត់គាត់ថាគាត់ពុះពារគ្រប់ឧបសគ្គទាំងអស់!!

ក៖ហ្នឹងហើយ ចាំ!!

ខ៖ ញ៉ុមស្រលាញ់គាត់ណាស់។

ក៖
គឺត្រូវតែអញ្ចឹងហើយសៀវព្រឹងបើគិតម៉េចៗអោយចេញអែលឌើរទៅរឹងតែល្អថែមទៀតហើយ
ហ្នឹងហើយ!!អញ្ចឹងអ្នកមីងសំរាប់សំនួរមួយចុងក្រោយមានអីមានពាក្យពេចន៍អីចង់ផ្តែផ្តាំកូន
ចៅជំនាន់ក្រោយម៉េចដែរអញ្ចឹងហាំ??

ខ៖ ញ៉ុមមានផ្តែផ្តាំអីទេ
គ្រាន់តែដូចថាចង់អោយតែកូនចៅជំនាន់ក្រោយគ្រាន់តែធ្វើតែល្អទេដើរតាមផ្លូវទ្រង់ដើរតាមផ្លូវល្អហើយ!!

ក៖ចា៎!!

ខ៖
មើលញ៉ុមហ្នុំកាលពេលមិនទាន់ដើរតាមផ្លូវទ្រង់ហា៎ញ៉ុមកាន់សាសនាចក្រមួយនេះហា៎គឺញ៉ុមធ្វើអំពើខុសហើយខុសទៀតរហូត !!

ក៖តែឥឡូវកែប្រែជីវិតអ្នកមីងអោយស្រស់បំព្រងតែម្តង!!

ខ៖ ចា៎!!ស៊ីស្ទើរសូម្បីតែញ៉ុមហា៎ក៏កុហកខ្លួនឯងដែរ កុហកត្រឹមម៉ែញ៉ុម
ហ៊ីង៉ែងកាលណាឈប់ផឹក?ញ៉ុមថាញ៉ុមឈប់ហើយ បានតែមួយខែយូរបំផុតមួយខែហា៎!!

ក៖ចា៎!!

ខ៖ មួយខែញ៉ុមផឹកមួយខែហើយពេញញ៉ុមឈប់ផឹក
ហើយតែតែបានរៀងខឹងចិត្តអីបន្តិចបន្តួចគឺបីបួនថ្ងៃមួយអាទិត្យហ្នឹងផឹកដឹរេចរហូត
អញ្ចឹងបានថាដល់ពេលហើយតាំងពីអាអូនចេះណែនាំស៊ីស្ទើរសុខចេះតែមកលេងអីអញ្ចឹងមកសួរសុខទុក្ខអីអ៊ីចឹង។

ក៖ចា៎!!

ខ៖ដូចថាគាត់ជួយណែនាំអីអញ្ចឹងហា៎!!

ក៖ចា៎!!

ខ៖ ដល់ពេលបានជឿជាក់លើព្រះអញ្ចឹងទៅបានដើរទៅផ្លូវល្អរហូតមកដល់រាល់ថ្ងៃហ្នឹង។

ក៖ ហើយម្តាយអីវ៉ាន់អីលែងពិបាកចិត្តអីអស់ហើយហី?

ខ៖ ចា៎!!លែងពិបាកចិត្តហើយ!!

ក៖អ៊ំអីវ៉ាន់អីហ្នឹង។

ខ៖ លើកមុនគាត់ពិបាកចិត្តញ៉ុម ពិបាកចិត្តកូនច្រើន ពិបាកចិត្តញ៉ុមផងពិបាកចិត្តប្អូនញ៉ុមផង
ញ៉ុមហាំកាលពេលញ៉ុមនៅផឹកដល់ថ្មើរហ្នឹងអីវ៉ាន់ហិជូនកាលញ៉ុមនិយាយហា
ម៉ែញ៉ុមនិយាយអត់បាន
អត់ដឹងថាគាត់ហ្នឹងជាអ្នកមីងគុណរបស់ខ្លួនឯងទេណាស់ហ៊ានតែថាអីតិចតួច
ថាអីតិចតួចហ្នឹងប្រចោរគេ ប្រចោរគាត់គាត់ជាម៉ែយើងផង!!

ក៖ ចំប្រចោរម៉ែទៀតមីង សាហាវម៉ងពេលមុន?

ខ៖ ចាសាហាវណាស់!!ជេរក៏ជេរ!!ថាមិនបាច់ចេះទេរឿងញ៉ុម
សុទ្ធតែជំទៀលដាក់ម៉ែទៀតហាំ!!

ក៖ ហ្នឹងហើយមីងឆ្នាស់ប៉ុណ្ណាហ្ន៎គ្រាន់តែចេញមកហ្ន៎!!

ខ៖ ហ្នឹង សុទ្ធតែអញ្ចឹងហាំ ហើយរករឿងអញ្ចឹងដាក់គាត់ ហើយដល់ញ៉ុមចូលទៅ
ចូលកាន់ជឿតាមព្រះទៅញ៉ុមដូចថាអាចរិកអីចឹងលែងមានចំពោះញ៉ុមហាំ!!

ក៖ចាំ!!មីងព្យាយាមទៅអោយជាប់
ញ៉ុមដឹងថាទោះថាឥឡូវក៏ពីមុនមកជួបទុកលំបាកមែនតែតិចទៀតមីងលែងអីហើយ!!

ខ៖ ញ៉ុមថាអញ្ចេកញ៉ុមអានព្រះគម្ពីរអត់ចាំហើយទៅអត់ចាំខ្ញុំនៅតែទៅ
ញ៉ុមរាល់ថ្ងៃញ៉ុមព្យាយាមទៅ ញ៉ុមទៅច្រើនតែពិធីសាក្រាម៉ង់ហើយញ៉ុមទៅផ្ទះហើយ!!

ក៖ ហ្នឹងហើយយើញ។

ខ៖ ញ៉ុមអត់ដែលនៅទេ
ព្រោះរៀនធ្វើអីបើរៀនភ្លេចដដែលហ្នឹងញ៉ុមអត់នៅរៀនញ៉ុមខ្ជិលណាស់!!!

ក៖ចាំ!!

ខ៖ញ៉ុមមកផ្ទះរហូតហ្នឹងចប់តែកម្មវិធីហ្នឹងញ៉ុមមកផ្ទះហើយហើយដល់ពេលទឹមតែឥឡូវញ៉ុម
ថាអញ្ចេក
អាអូនអីវ៉ាន់ចេះតែនិយាយហាំថាម៉ែឯងចាំទៅចេះតែអង្គុយស្តាប់ទៅក៏មានចំនុចណាដែលម៉ែ
ឯងត្រូវចាំដែរថាអញ្ចឹងហាំ!!

ក៖ចាំ!!

ខ៖ ដល់ពេលហើយញ៉ុមចេះតែព្យាយាមទៅ មួយរយៈហ្នឹងញ៉ុមចេះតែនៅដល់ចប់ៗម៉ោង!!

ក៖ហ៊ឺៗ!ល្អ!

ខ៖ចេះតែព្យាយាមខ្លួនឯងអញ្ចឹងទៅណាស់
បើថាយើងមិនចាំអីកន្លែងណាចំនុចណាក្រែងលោរយើងចាំកន្លែង
យើងដឹងថាអានេះយើងចង់ដឹងថាពេលមានបញ្ហាយើងដឹងកំហុសកន្លែងនេះវាត្រូវនិយាយអ
ញ្ចេះកន្លែងនេះគេកែប្រែយ៉ាងម៉េចអញ្ចឹងញ៉ុមដឹង!!

ក៖ចាំទោះម៉េចក៏បានដាស់តឿនខ្លួនឯងហាំ!!

ខ៖ កាលហ្នឹង កាលហ្នឹង
ថាបងស៊ីស្មើរមែនឡើងនិយាយហ្នំ??ថាអញ្ចេកមនុស្សយើងទាល់តែចេះគ្រប់គ្រងអារម្មណ៍យើ
ងបានជាមនុស្សល្អមែនទេ!!ចង់និយាយអ៊ីជឹងហាំញ៉ុម
រាល់ថ្ងៃគ្រប់គ្រងខ្លួនឯងអត់ទាន់បានទេ!!

ក៖ចាំ!!

ខ៖
តែធ្លាប់ធ្លាប់ឮអើរអ៊ែលឌើរអីឡើងនិយាយថាមនុស្សយើងទាល់តែយើងចេះគ្រប់គ្រងអារម្មណ៍
ខ្លួនយើងបានបានធ្វើជាមនុស្សបើអត់គ្រប់គ្រងខ្លួនឯងអត់បានយ៉ាប់ណាស់អញ្ចឹងហាំ!!

ក៖ ហ្នឹងហើយ។

ខ៖ហ្នឹង!!

ក៖ និយាយទៅយើងត្រូវចេះតែអញ្ចឹងបើសិនជាបណ្តោយៗទៅធ្វើបាបតែខ្លួនយើងហ្នឹងហាំ!!

ខ៖ចាំ!!

ក៖ទោះញ៉ុមអីវ៉ាន់ក៏ដោយពេលខ្លះញ៉ុមដឹងថាពេលខ្លះមានការពិបាកមានចំនុចខ្សោយរៀងៗ
ខ្លួនដែរ តែព្យាយាមដើម្បីយកឈ្នះមួយហ្នឹងដើម្បីពង្រឹងទៅថ្ងៃខាងក្រោយ!!

ខ៖ហ្នឹង!!

ក៖ដូចពេលញ៉ុមបង្រៀនដូចនៅថ្ងៃអាទិត្យអ៊ីចឹងដូចជាពេលខ្លះជាគ្រូធម្មតាយើងត្រូវតែសួរសិស្សហើយ។

ក៖ចាំ!!

ខ៖ តែបើគាត់មានអីមានគំនិតអីអីអញ្ចឹងមកប្រាប់មក!!

ខ៖ចាំ!!

ក៖បើសិនជាអត់យល់កន្លែងណាសួរ!!

ខ៖ចាំ!!

ក៖ហើយបើសិនជាអត់ចេះកន្លែងណាឬក៏អត់យល់យើងត្រូវតែជួយបំពេញឬក៏មានសំនួរចោទសួរគ្នាទៅវិញទៅមកបានចេះទាំងអស់គ្នា បើសិនជាតែញ៉ុមតែម្នាក់ឯងក៏អត់កើតដែរ អញ្ចឹងឆ្ងល់អីកន្លែងណាសូមសួរ!!

ខ៖ ចាំហើយស៊ីស្ទើរពេលញ៉ុមទៅម៉ោងអ្នកគ្រូបុប្ផាហ្នំ បុប្ផាអោយញ៉ុមអធិស្ឋានហ្នំ!!

ក៖ចាំ!!

ខ៖ហើយញ៉ុមប្រកែក ថាហ្នំញ៉ុមអ់តសូវចេះអធិស្ឋានទេហើយទៅម៉ែស៊ីស្ទើរហើ គាត់ចេះតែនិយាយអ៊ីចឹងថាព្រះចង់ដឹងសំដីយើងណាស់ ចង់ដឹងពេលកូនរៀននិយាយតិចៗណាស់!!

ក៖ចាំ!!

ខ៖ គាត់និយាយសំដីគាត់កន្លែងហ្នឹងល្អណាស់ គាត់និយាយដូចថាធម្មតាកូនទឹមតែរៀននិយាយហាំ!!ឪពុកម្តាយចង់ដឹងពេលកូនរៀននិយាយហ្នឹងហើយមែនទេ?

ក៖ ហ្នឹងហើយ!!

ខ៖
ញ៉ុមយល់អាកន្លែងគាត់យល់កន្លែងហ្នឹងហាំ!!ពេលទឹមកូនយើងចេះហៅប៉ាចេះហៅម៉ាក់ហាំ!! យើងមានអារម្មណ៍ថាសប្បាយចង់អោយកូនហៅណាស់មែនទេ!!

ក៖ ហ្នឹងហើយអឺចឹងដូចគ្នាមីង!!

ខ៖ ហ្នឹងហ្នឹង គាត់និយាយចំនុចកន្លែងហ្នឹងញ៉ុមយល់ តែតែអត់ចេះ អត់ចេះអធិស្ឋានអត់បានក្បោះក្បាយក៏ដោយក៏យើងចេះតែនេះទៅធ្វើម៉េចបើយើងហ្នឹង!!

ក៖
ហ្នឹងហើយល្អហើយអ្នកមីងដែលអ្នកមីងយកបទពិសោធន៍របស់ពួកគាត់យកមករៀនអញ្ចឹងណាស់!!

ខ៖ចាំ!!

ក៖អញ្ចឹងពួកគាត់នៅក្នុងហ្នឹងពេលខ្លះមនុស្សម្នាក់ៗតែងតែមានកំហុសឬក៏ម៉េចអីវ៉ាន់អញ្ចឹងហើយ!!

ខ៖ ចាំ!!

ក៖ប៉ុន្តែពួកគាតនៅហ្នឹងភាគច្រើនគាត់ចូលចិត្តលើកទឹកចិត្តគ្នាភាគច្រើន!! អញ្ចឹងថ្ងៃណាមួយបើសិនមានកំហុសឆ្គងអីមួយកើតឡើងយថាហេតុឬក៏គាត់អត់មានបំណងអីអ្នកមីងមិនបាច់ខឹងមិនបាច់អីទេ
ដោយសារអ្នកដែលនៅជឿលើដំណឹងល្អរបស់ព្រះគឺមានពេលដែលពួកគាត់ដឹងខ្លួនរហូតថា ញ៉ុមបានធ្វើមួយនេះខុសអញ្ចឹងញ៉ុមត្រូវតែកែប្រែអីវ៉ាន់អីអញ្ចឹង !!

ក៖
ញ៉ុមតែងតែមានបញ្ហាអីញ៉ុមតែសួរអាអូនហាំ!!អាអូនថាអញ្ចេកម៉ាក់យើងទៅព្រះវិហារគឺយើងចង់ដឹងពីដំនឹងរបស់ព្រះ យើងមិនមែនដូចថា!! យើងទៅគឺដើម្បីព្រះ!!ក៖ចាំ!!ខ៖មិនមែនទៅ!!

ក៖មនុស្ស!!

ខ៖
មនុស្សទេអាអូននិយាយប្រាប់ញ៉ុមថាអញ្ចឹងហា៎!!ក៖ចា៎!!ខ៖អាអូនញ៉ុមនិយាយប្រាប់ញ៉ុមចំនុចល្អៗណាស់ប្រាប់ញ៉ុមហា៎!!ពេលណាដែលញ៉ុមពិបាកចិត្តញ៉ុមតែងតែសួរហា៎!!

ក៖ ចា៎ហ្នឹងហើយអ៊ីចឹងសៀវព្រីងអ្នកដែលជាគំរូរបស់អ្នកមីង
អញ្ចឹងសួរគាត់ហើយញ៉ុមសង្ឃឹមថាសៀវព្រីងគាត់នឹងបានទៅព្រះវិហារនៅថ្ងៃអាទិត្យវិញ!!

ខ៖ ញ៉ុមសួរដែរអាអូនម៉េចអត់បានមក វាថាអញ្ចេក
ស៊ីស្ទើរធម្មតាថ្ងៃធ្វើការគ្នាដំបូងអញ្ចឹងវាតែងតែធ្វើ!!ក៖ចា៎!!ខ៖ព្រោះយើងសាកល្បងការងារហា៎!!
កុំអោយយើងសាកល្បងការងារអីអញ្ចឹងយើងអាលែងតែឈប់អញ្ចឹងខ្លាចគេអត់ពេញចិត្តយើងអញ្ចឹងហ្នូ!! គេអត់សប្បាយចិត្តនឹងយើងទេ!!ដល់ពេលយើងធ្វើការរៀងបានយូរតិចបានរៀងអាហ្នឹងយើងជាធម្មតាមួយអាទិត្យវាតែងមានថ្ងៃឈប់មួយថ្ងៃហើយណាស់
តែត្រូវថាអ្នកនៅពីមុនពីមុនគេត្រូវយករើសថ្ងៃអាទិត្យអីអស់ហើយណាស់!!

ក៖ហ៊ុៗ!!

ខ៖ ហើយចាំមើលថាដល់ពេលចូលយូរតិចចាំសុំគេម្តង!!វានិយាយអញ្ចឹងហា៎!!

ក៖ ចា៎ហ្នឹងហើយ!!អញ្ចឹងឮនិយាយអ៊ីចឹងដែរ!!

ខ៖ ហ្នឹង។

ក៖ហើយអញ្ចឹងអ្នកមីងមានអីចង់ផ្តែផ្តាំអីគេទៀតទេ?

ខ៖អត់ទេមានតែប៉ុណ្ណឹងទេ។

ក៖ចាអញ្ចឹងអ្នកមីងអរគុណច្រើនសំរាប់ការរៀបរាប់ជីវិតដ៏ក្បោះក្បាយរបស់អ្នកមីងបានប្រាប់ទុកអោយកូនចៅរបស់សៀវព្រីង!!

ខ៖ចា៎!!

ក៖ក៏ដូចជាកូនខ្មែរជំនាន់ក្រោយបានរៀនពីជីវប្រវត្តិរបស់អ្នកមីងហា៎អ្នកមីង!!

ខះចាំ!!

កះអញ្ចឹងអរគុណច្រើន។

ខះចាំ។។